ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៨៧/២៦ ស.ប.ក

# របាយការណ៍
## ស្តីពី
## ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំត្រីមាសទី១ និងទិសដៅត្រីមាសទី២ ឆ្នាំ២០២៦

### I. ស្ថានភាពទូទៅ

ពិភពលោក កំពុងនៅតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ និងសង្គ្រាមបង្ហូរឈាម វិបត្តិនយោបាយបានកើតឡើង ជាបន្តបន្ទាប់ និងរាលដាលពីតំបន់មួយទៅតំបន់មួយ ចរន្តគាំពារនិយម ភាពក្រីក្រចេះតែមានចំនួនកើនឡើងជាបន្តបន្ទាប់ ជាបុព្វហេតុជំរុញឱ្យមនុស្សរាប់លាននាក់ បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាវំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង និងប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន ការកេងប្រវ័ញ្ចជាច្រើនរូបភាព និងអំពើជួញដូរមនុស្ស។ អំពើជួញដូរមនុស្ស ការរំលោភសិទ្ធមនុស្ស រំលោភសណ្តាប់ធ្នាប់ពិភពលោក ច្បាប់អន្តរជាតិ ជារឿងស្មុគស្មាញ និងជាបញ្ហាដ៏ធំមួយនៃសង្គមមនុស្សជាតិក្នុងពិភពលោក ដែលកើតឡើងដោយសារកត្តារួមផ្សំជាច្រើន ។

ប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូរបែប និងការផ្សព្វផ្សាយ នៃបណ្តាញសារព័ត៌មាននានាមួយចំនួន បានលាយឡំទាំងព័ត៌មានពិត និងមិនពិត រួមទាំងនិន្នាការ និងភូមិសាស្ត្រនយោបាយផងនោះ បានវាយតម្លៃអំពីស្ថានភាពនៃបទល្មើសជួញដូរមនុស្សនៅកម្ពុជា។ ទន្ទឹមនឹងនោះការចោទប្រកាន់ពីបណ្តាប្រទេសមួយចំនួន ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា ក៏បានធ្វើឱ្យមានការភាន់ច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលផ្ទុយពីឆន្ទះរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្ថានភាពពិតជាក់ស្តែងនៅកម្ពុជា ។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការ ទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានា ក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុសក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scam) ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ នៃសង្គមជាតិ។

នៅក្នុងត្រីមាសទី១ នេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងដោយមានការចូលរួមគាំទ្រ សហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លើយតបនឹងស្ថានភាពប្រែប្រួល ពិបាកប៉ាន់ស្មាននៃបទល្មើសជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតដែលបង្កឡើងដោយឧក្រិដ្ឋជន រួមទាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការបង្ការ ទប់ស្កាត់

#### ក.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន ៦២,៧២៣លើក មានអ្នកចូលរួមសរុបចំនួន ២,៩៨៥,៦៥៦នាក់ ក្នុងនោះស្ត្រី ១,៥៩៩,៦៥៣នាក់ ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត (ថ្នាក់ជាតិ) | ០១ | ២,៥០០ | ៧៥០ |
| | -រាជធានីភ្នំពេញ(វិ.ជម្ពូវ័ន្ត, វិ.ភ្នំពេញថ្មី, វិ.ពញាពន់ សាលា AIS) | ១៦ | ៣,៦៥០ | ១,៨៦៣ |
| | -ខេត្តកំពង់ចាម | ០១ | ៦១៧ | ២៩០ |
| | -ខេត្តក្រចេះ | ០១ | ៤៨៣ | ២៧៥ |
| ២ | ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០២៥ | ០១ | ២,៩០០ | ៨៧៩ |
| | -ថ្នាក់ក្រោមជាតិ (១៦ខេត្ត) | ១៦ | ៦,៨០៤ | ២,៤៣៣ |
| ៣ | ច្បាប់ វេទិកាសាធារណៈ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព | ៦២,២៩១ | ២,៩២៨,៦៩៤ | ១,៥៧៣,៧៩៣ |
| ៤ | កម្មវិធីផ្សេងៗ | ៣៩៦ | ៤០,០០៨ | ១៩,៣៧០ |
| | **សរុប** | **៦២,៧២៣** | **២,៩៨៥,៦៥៦** | **១,៥៩៩,៦៥៣** |

*(សម្គាល់៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)*

❖ **យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត**

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** សហជាមួយ ក្រុមប្រឹក្សាជាតិដើម្បីកុមារ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហភាពសហព័ន្ធយុវជនកម្ពុជា និងគាំទ្របច្ចេកទេសដោយក្រុមហ៊ុន Smart Axiata មូលនិធិ CBRD Fund អង្គការ APLE, Mission Alliance, Child Fund, Auscam, HAGAR, MARICI, អង្គការម្លប់តាប៉ាង បានប្រារព្ធកម្មវិធី យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ក្រោមប្រធានបទ «ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង ដោយមានអ្នកចូលរួមសរុបប្រមាណ ២,៥០០នាក់ ស្រី ៧៥០នាក់។

▪**ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** សហការជាមួយ រដ្ឋបាលខេត្តកំពង់ចាម ខេត្តក្រចេះ និងគ្រឹះស្ថានសិក្សានៅរាជធានីភ្នំពេញ(វិទ្យាល័យជម្ពូវ័ន្ត វិទ្យាល័យភ្នំពេញថ្មី វិទ្យាល័យពញាពន់ សាលាអន្តរជាតិ AIS) និងគាំទ្របច្ចេកទេសដោយក្រុមហ៊ុន Smart Axiata និងអង្គការ APLE, Child Fund បានប្រារព្ធកម្មវិធី យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ក្រោមប្រធានបទ «**ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ**» ចំនួន ១៨លើក ដោយមានការអញ្ជើញចូលរួមជាអធិបតី លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ ឯកឧត្តមអគ្គលេខាធិការរង មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ និងសិស្ស សរុបប្រមាណ ៤,៧៥០នាក់ ស្រី ២,៤២៨នាក់។

❖ **ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥**

▪អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សហការជាមួយ ក្រសួងស្ថាប័ន រដ្ឋបាលរាជធានីភ្នំពេញ និងគាំទ្របច្ចេកទេសដោយអង្គការ ERIKS, សម្ព័ន្ធចាប់ដៃ, AIM, IJM, HAGAR, DAI CAMBODIA, CPU និង MARICI បានប្រារព្ធ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ «រួមគ្នាដើម្បីកម្ពុជា គ្មានអំពើជួញដូរមនុស្ស និងគ្មានអំពើឆបោកតាមអនឡាញ» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ដោយមានការអញ្ជើញចូលរួមពី តំណាងព្រះពុទ្ធសាសនាទាំងពីរគណៈតំណាងស្ថាប័នព្រឹទ្ធសភា រដ្ឋសភា សមាជិករាជរដ្ឋាភិបាល រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ តំណាងរាជបណ្ឌិត្យសភាកម្ពុជា អភិបាល អភិបាលរង ស្នងការ ស្នងការរង រាជធានី ខេត្ត តំណាងសាសនាធំៗទាំងបី តំណាងស្ថានទូត ស្ថានតំណាង ប្រចាំនៅព្រះរាជណាចក្រកម្ពុជា កងកម្លាំងប្រដាប់អាវុធ សិស្ស និស្សិត សហភាពសហព័ន្ធយុវជនកម្ពុជា យុវជនកាយឫទ្ធិ យុវជនកាកបាទក្រហម វិស័យឯកជន ព្រមទាំងអង្គការដៃគូ សរុបប្រមាណ ២,៩០០រូប ស្រី ៨៧៩រូប។

▪គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ បានរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ក្រោមប្រធានបទ "រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" សរុបចំនួន **១៦លើក** អ្នកចូលរួមចំនួន ៦,៨០៤នាក់ ស្រី ២,៤៣៣នាក់ ក្នុងនោះមានខេត្ត៖ ស្វាយរៀង ៤៥០នាក់(ស្រី១៩៣), សៀមរាប១,០០០នាក់(ស្រី៤០៩), បន្ទាយមានជ័យ៧០០នាក់(ស្រី៣០០), កំពង់ចាម ៦០៦នាក់(ស្រី៣៨៨), កំពង់ឆ្នាំង៥២០នាក់, ឧត្តរមានជ័យ៤០០នាក់, តាកែវ២៨៤នាក់(ស្រី២៣), ស្ទឹងត្រែង ៣០៤នាក់, កែប៣១២នាក់, មណ្ឌលគិរី៣២៩នាក់(ស្រី១៤៣), ត្បូងឃ្មុំ៣៧៨នាក់(ស្រី១៨៤), ក្រចេះ២៤៥នាក់ (ស្រី១១៧), ព្រះវិហារ២លើក ២៧៥នាក់(ស្រី៧៥), ព្រះសីហនុ៤៨១នាក់(ស្រី២៥៦), កណ្តាល៥២០នាក់ (ស្រី៣៤៥)។

❖ **ការផ្សព្វផ្សាយវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ វេទិកាសាធារណៈ | | | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ថ្នាក់ជាតិ | | | | | | | |
| ១ | គ.ជ.ប.ជ | ១០ | ១,៤១៥ | ៧២៦ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | ក្រសួងកិច្ចការនារី | ០២ | ៣៥១ | ៣៣៦ | | | |
| ៣ | កាកបាទក្រហមកម្ពុជា | ៨៩ | ២,៣៤៥ | ១,០៥១ | | | |
| រាជធានី ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ១០០ | ៥,៩៦៧ | ៤,០៤២ | ២៩៥ | ៦៧,៤៦១ | ៣៤,៣៦១ |
| ២ | កណ្តាល | ២,៥៨៣ | ១១០,៥៨០ | ៦៩,១១៥ | ៣,២៨៦ | ១៧៥,១៧៣ | ៨៧,២៩៥ |
| ៣ | បាត់ដំបង | ១,៩៩៨ | ៦៧,៣១៩ | ៣៧,៨៩២ | ២,៥៦៦ | ១៣៩,២២៣ | ៧៧,៧០៨ |
| ៤ | ពោធិ៍សាត់ | ១,០៦៩ | ៤៤,៩៩០ | ២២,៥៧១ | ១,៨៦៥ | ១៣៧,១០៤ | ៦៣,៣៥៦ |
| ៥ | សៀមរាប | ៣,០៤៤ | ១១១,៩៦២ | ៧២,៣៩២ | ២,៨៧៣ | ២៣១,៦១១ | ១៤២,១៩៩ |
| ៦ | កំពង់ឆ្នាំង | ២,២៦៤ | ១២៥,៧៥៨ | ៤៦,៤៨៩ | ១,៦១១ | ៦៥,១៧៤ | ២៤,៧១៥ |
| ៧ | កំពង់ចាម | ៦,៥៤៩ | ៣៥៦,១២៩ | ១៨៤,៧២២ | ២,៩៤៣ | ១២៥,៨៩១ | ៧០,៧៣០ |
| ៨ | ព្រះសីហនុ | ២៧២ | ១០,៣៩៣ | ៤,៣៩១ | | | |
| ៩ | ព្រះវិហារ | ០៥ | ១៧៥ | ៧៤ | ២១ | ១,៥៤៧ | ៩៧១ |
| ១០ | ស្វាយរៀង | ១,៣៨៧ | ៣៦,៧៨០ | ៣៤,២៨០ | ១,១៧៦ | ៣៤,៣១៨ | ២៣,៩៥៦ |
| ១១ | ប៉ៃលិន | ១០៧ | ១,៩៤៩ | ១,០៧៧ | | | |
| ១២ | កោះកុង | ៤,៥៥៥ | ៨៣,៦១៣ | ៣៩,៥៩០ | ១,១៩០ | ២០,២៥១ | ៩,២៥៥ |
| ១៣ | កំពត | ៩៨៩ | ៤៩,៣៤៧ | ២៦,៨៧៩ | ១,០០៧ | ៤៩,៣៩១ | ២៦,៨៦០ |
| ១៤ | តាកែវ | ១,០៩៤ | ៤៨,៦២៧ | ២៧,១១២ | ៣០៧ | ១១,៨៥៦ | ៦,៣៧៧ |
| ១៥ | ក្រចេះ | ១៩៨ | ៨,៣២៤ | ៤,១៧៧ | | | |
| ១៦ | កែប | ៤៧២ | ២០,០៦២ | ១១,៥៦៨ | ២៥២ | ៤១,៤២៧ | ១៧,៦១១ |
| ១៧ | កំពង់ស្ពឺ | ១,៩៦៦ | ៩៨,៧៧៩ | ៥៤,៧៨៩ | ៤១១ | ១៦,៣៩២ | ៨,៨២៣ |
| ១៨ | ស្ទឹងត្រែង | ៥០១ | ១៨,៩០១ | ១០,៥៩៨ | ៦១០ | ៤១,១០៦ | ២២,១៤៥ |
| ១៩ | រតនគិរី | ៧០៥ | ៣៤,៥៩៣ | ១៧,៧០៥ | ១,២៧១ | ៦០,៧១៦ | ៣១,១៤០ |
| ២០ | ព្រៃវែង | ១,៩៦៧ | ៦១,៨០២ | ៣៣,៤៧០ | ២,៩៤៣ | ១៧៥,១៣៧ | ៩៤,៩០៦ |
| ២១ | ត្បូងឃ្មុំ | ១២១ | ១១,២៧៣ | ៥,២៦៤ | ៣៥៣ | ១០,៦១១ | ៤,៧៦២ |
| ២២ | ឧត្តរមានជ័យ | ២០ | ១,១២៣ | ៧៧៤ | ៣០៦ | ១៣,៤២៧ | ៧,៤៨៦ |
| ២៣ | មណ្ឌលគិរី | ៧៥ | ៣,២៦៣ | ១,៥៤៩ | ៤៩០ | ១៣,៣៣៨ | ៦,២៥៤ |
| ២៤ | កំពង់ធំ | ៨៥៩ | ៣០,២១២ | ១៧,៥៧៤ | ១,៦០៥ | ១១៤,៧៧៩ | ៦០,៥៥៣ |
| ២៥ | បន្ទាយមានជ័យ | ៤៥៦ | ១១,២១៦ | ៧,២៧១ | ១,៤៥៣ | ២៦,០៨៣ | ១៥,៨៥២ |
| សរុប | | ៣៣,៣៥៦ | ១,៣៥២,៥៦៧ | ៧៣៥,៣៦៥ | ២៨,៨៣៤ | ១,៥៧២,០១៦ | ៨៣៦,៣១៥ |
| សរុបរួម | | ៦២,២៩១ លើក | | ២,៩២៨,៦៩៤ នាក់ | | ១,៥៧៣,៧៩៣ នាក់ | |

❖ **ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ**

| ល.រ | ក្រសួង-ស្ថាប័ន/រាជធានី-ខេត្ត/អង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ក្រសួងធម្មការនិងសាសនា | ០៩ | ១,៧៤២ | ៦៣៤ |
| ២ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ០៥ | ១,២៤១ | |
| ៣ | ខេត្តកណ្តាល | ១៣០ | ៣,៤២៥ | ១,៥១៦ |
| ៤ | ខេត្តកំពង់ចាម | ២៤ | ៨,៤៩៨ | ៥,៧៤៩ |
| ៥ | ខេត្តមណ្ឌលគិរី | ០៣ | ២៨៧ | ១៤០ |
| ៦ | ខេត្តប៉ៃលិន | ០២ | ៧៨ | ៣២ |
| ៧ | ខេត្តសៀមរាប | ៧៩ | ៨,៣៧០ | ៤,៨០៤ |
| ៨ | ខេត្តកំពង់ឆ្នាំង | ២១ | ១,៣៥២ | ៤២៨ |
| ៩ | ខេត្តស្វាយរៀង | ១២ | ២៥៨ | ១៥៤ |

| | | | | |
|---|---|---|---|---|
| ១០ | ខេត្តតាកែវ | ០១ | ២,៥៧៩ | ៥៧៨ |
| ១១ | ខេត្តកំពង់ស្ពឺ | ៨៩ | ៧,៣៨៨ | ៣,៤៧១ |
| ១២ | ខេត្តកែប | ០៧ | ២,៧៤៥ | ១,៣៤៣ |
| ១៣ | ខេត្តបន្ទាយមានជ័យ | ១២ | ១,៩៧៦ | ៤៥៨ |
| សរុប | | ៣៩៦ លើក | ៤០,០០៨ នាក់ | ១៩,៣៧០ នាក់ |

**ក.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់**

❖ **ការផលិត និងចែកផ្សាយសម្ភារផ្តល់ព័ត៌មាន និងអប់រំ** (IEC = Information Education Communication Materials)

▪ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ អង្គការអន្តរជាតិខាងការងារ (ILO)

-បានគាំទ្រមណ្ឌលធនធានពលករទេសន្តប្រវេសន៍ចំនួន ៣ នៅខេត្តបន្ទាយមានជ័យ កោះកុង, និង ខេត្តសៀមរាប និងសភាសម្ព័ន្ធសហជីពជាតិកម្ពុជា នៅខេត្តតាកែវ និងខេត្តកំពង់ស្ពឺ បានផ្សព្វផ្សាយខិត្តប័ណ្ណដល់ប្រជាពលរដ្ឋ និងអ្នកដែលមានបំណងស្វែងរកការងារធ្វើនៅក្រៅប្រទេសចំនួន ២,២៦៧នាក់ (ស្រី ១,៣១៩នាក់) អំពីការធ្វើទេសន្តប្រវេសន៍ប្រកបដោយសុវត្ថិភាព ឱកាសការងារ សិទ្ធិការងារ សុវត្ថិភាពការងារ និងសុខភាព លក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅរបស់ពលករនៅបរទេស កិច្ចគាំពារសង្គម ការវិលត្រឡប់មកវិញប្រកបដោយសុវត្ថិភាព និងការធ្វើសមាហរណកម្ម

-បានបន្តផ្សព្វផ្សាយឯកសារព័ត៌មានចំនួន ៣ប្រភេទ ដល់ពលករទេសន្តប្រវេសន៍ខ្មែរក្នុងផ្នែកនេសាទ និងកែច្នៃអាហារសមុទ្រ លើះ (១) ការធ្វើទេសន្តប្រវេសន៍ដោយសុវត្ថិភាព, (២) សិទ្ធិការងារ និង(៣) សុវត្ថិភាពការងារ និងសុខភាព នៅខេត្តគោលដៅចំនួន ៥ រួមមាន ខេត្តកោះកុង, បន្ទាយមានជ័យ, តាកែវ, កំពង់ស្ពឺ និងខេត្តសៀមរាប។

▪ លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ៖

| ល.រ | ខេត្ត | សកម្មភាព និងឧបករណ៍ផ្សព្វផ្សាយ | ចំនួនឧបករណ៍ | ចំនួនអ្នកទទួលបាន | ចំនួនស្ត្រី |
|---|---|---|---|---|---|
| ១ | ភ្នំពេញ | -ផ្សព្វផ្សាតាមរយៈ DVD Video (ផ្លូវថ្មើជើងចតុមុខ) | | ២,៤៤៣,០០០ | |
| ២ | សៀមរាប | -ខិត្តប័ណ្ណផ្សព្វផ្សាយ<br>-បដាអប់រំ | -៤០,៣៤០ប័ណ្ណ<br>-២៣ ផ្ទាំង | | |
| ៣ | កំពង់ចាម | -ខិត្តប័ណ្ណផ្សព្វផ្សាយ | -៣០០ប័ណ្ណ | | |
| ៤ | ព្រះវិហារ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | -៤៦ប័ណ្ណ | | |
| ៥ | បន្ទាយមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ៤៣៣ | ១៥១ |
| *សរុបខិត្តប័ណ្ណផ្សព្វផ្សាយ ៤០,៦៨៦ប័ណ្ណ ចងបដាផ្សព្វផ្សាយ ២៣ផ្ទាំង* | | | | | |

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

▪ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖

-បានផលិត និងផ្សព្វផ្សាយមាតិកាថ្មីអំពីសេវាការងារសាធារណៈលើគេហទំព័រការងារ កម្មវិធីការងារលើទូរស័ព្ទដៃវៃឆ្លាត និង Facebook ចំនួន ៦៦ដង

-ប្រជាពលរដ្ឋ សិស្សនិស្សិត បានចូលប្រើប្រាស់គេហទំព័រការងារទីភ្នាក់ងារជាតិមុខរបរ និងការងារចំនួន ៤៣០,៦០៦លើក

-បានផ្សព្វផ្សាយព័ត៌មានអំពីទីផ្សារការងារតាមរយៈទំព័រ Facebook ដោយមានអ្នកទទួលព័ត៌មានសរុបចំនួន ៤២៨,៩០៩នាក់ និងព័ត៌មានតាមរយៈ TikTok ចំនួន ២,៧៥០,៧៨៤លើក

-បានផលិតស្ប៉តជាសំឡេង ស្តីពីសេវាការងារ និងព័ត៌មានទីផ្សារការងារ ចំនួន១២ស្ប៉ត និងចាក់ផ្សាយចំនួន ១,២០០ដង

-អ្នកប្រើប្រាស់សេវាតាមរយៈកម្មវិធីស្វែងរកការងារលើទូរស័ព្ទវៃឆ្លាតសរុបចំនួន ៤២៣នាក់

-បានផ្សព្វផ្សាយអំពីការផ្តល់សេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់សាធារណជន សិស្សានុសិស្ស និស្សិត ជាពិសេស យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ តាមរយៈវិទ្យុ ៦២ដង, ទូរទស្សន៍ចំនួន ៥ដង, សារព័ត៌មានចំនួន ៥ដង, គេហទំព័រចំនួន ២៣៥ដង និងតាមបណ្តាញសង្គម (Facebook) ចំនួន ៤,៥៦១ដង ដែលមានអ្នកចូលមើលសរុបចំនួន ៣,៨៨៦,០៨៩លើក និងចែករំលែកបន្តចំនួន ៦១,៣៣៤លើក

-បានរៀបចំបញ្ជីសារអេឡិចត្រូនិកខ្លី (Pushing Message) ស្តីពីការធ្វើទេសន្តរប្រវេសន៍ការងារដោយសុវត្ថិភាពតាមបណ្តាញទូរស័ព្ទដៃ

-បានដាក់ឱ្យដំណើរការប្រព័ន្ធ Hotline លេខ១២៩៧ ដោយដាក់ឱ្យមានអ្នកប្រចាំការ ៧ថ្ងៃ/សប្តាហ៍ ដើម្បីផ្តល់ព័ត៌មានទៅសហគ្រាស ក្រុមហ៊ុន រោងចក្រ

-បានបង្កើនការផ្សព្វផ្សាយប្រព័ន្ធ Hotline លេខ១២៩៧ និងប្រព័ន្ធ Telegram Bot "ស្វែងរកការងារ-MLVT" ដោយបានដំឡើងផ្ទាំងប៉ាណូផ្សព្វផ្សាយបន្ថែមនៅតាមផ្លូវជាតិសំខាន់ៗ។

▪ **ក្រសួងព័ត៌មាន៖**

-បានផលិតវីដេអូមតិមហាជនក្នុងកម្មវិធី «អត្ថប្រយោជន៍អ្នក» ចំនួន០៣៖ (១)សម្រង់មតិរយៈពេល ៥នាទី ស្តីពីការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់យុវជន ១.៥លាននាក់, (២)សម្រង់មតិរយៈពេល ៣នាទី ស្តីពីការផ្តល់ជំនាញជាក់លាក់ និងការងារធ្វើដល់អតីតពលករ និងអ្នកកំពុងស្វែងរកការងារធ្វើ និង(៣)សម្រង់មតិរយៈពេល៣នាទី ស្តីពីការផ្តល់ជំនាញដេរ ឧបត្ថម្ភក្នុងពេលរៀន និងផ្តល់ការងារធ្វើដល់អតីតពលករមកពីប្រទេសថៃ បានផ្សព្វផ្សាយវីដេអូ ស្តីពីឱកាសការងារ ចំនួន ២៥,២១២កន្លែង នៅរាជធានីភ្នំពេញ ជូនបងប្អូនប្រជាពលរដ្ឋ ជាពិសេសអតីតពលករដែលវិលត្រឡប់មកប្រទេសកម្ពុជាវិញ។

▪ **លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ៖**

| ល.រ | ខេត្ត | បណ្តាញផ្សព្វផ្សាយ | ចំនួនលើក | ចំនួនអ្នកទស្សនា/Views |
|---|---|---|---|---|
| ១ | សៀមរាប | -វិទ្យុជាតិ<br>-ខ្សែភាពយន្តវីដេអូអប់រំ | ៣៩៨ | |
| ២ | ត្បូងឃ្មុំ | -វិទ្យុជាតិ | ៣៦៧ | |
| ៣ | ប៉ៃលិន | -វិទ្យុជាតិ/ទូរទស្សន៍ | ១,៤៤០ | |
| ៤ | ព្រៃវែង | -វិទ្យុជាតិ<br>-ផ្សព្វផ្សាយឱកាសការងារតាមតេឡេក្រាម | ១៥០<br>៤៦ | ១,៣៩៥ |
| ៥ | កោះកុង | -ផ្សព្វផ្សាយស្ប៉តអប់រំ ស្តីពីការជួញដូរមនុស្សជាអំពើខុសច្បាប់តាមរយៈវិទ្យុ | ៤៥០ | |
| ៦ | កំពង់ចាម | វិទ្យុ | ១២ | |

| | | | | |
|---|---|---|---|---|
| ៧ | កំពង់ស្ពឺ | វិទ្យុ -ស្ពតអប់រំ | ១,៨០០ | |
| ៨ | តាកែវ | វិទ្យុ -ស្ពតអប់រំ | ២៧០ | |
| ៩ | រាជធានីភ្នំពេញ | ហ្វេសប៊ុក, តេឡេក្រាម, តិចតុក | ១២០ | |
| ១០ | កែប | វិទ្យុ | ០៥ | |
| ១១ | បន្ទាយមានជ័យ | វិទ្យុ | ០៨ | |
| *សរុប* | | | *៥,០៦៦ លើក* | *១,៣៩៥ នាក់* |

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍**

▪ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖

-សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការលើកកម្ពស់ការការពារពលករទេសន្តរប្រវេសន៍ពីអាស៊ីទៅធ្វើការនៅប្រទេសជប៉ុន តាមរយៈប្រព័ន្ធអនឡាញ ដើម្បីចែករំលែកអំពីសកម្មភាពសំខាន់ៗរបស់សមាគម ACRA ក្នុងការបង្កើន និងលើកកម្ពស់ការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌ និងសកម្មភាពក្នុងការអនុវត្តក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ដែលមានការគាំទ្រក្នុងការអនុវត្តគម្រោងត្រីកោណក្នុងតំបន់អាស៊ានតាម រយៈអង្គការអន្តរជាតិខាងការងារ ILO និងទទួលស្គាល់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំដោយអង្គការអន្តរជាតិខាងការងារ (ILO)។

-បានជួបផ្តល់បទសម្ភាសន៍ជូនអង្គការអន្តរជាតិបម្រើសុខភាពប្រជាជន ដើម្បីស្វែងយល់បន្ថែមអំពីកង្វល់តម្រូវការ និងបញ្ហាប្រឈមនានាទាក់ទងនឹងសុវត្ថិភាពកុមារ ក្នុងគោលបំណងស្វែងយល់ពីទិដ្ឋភាពទីផ្សារ និងឱកាសសម្រាប់ផលិតផល/សេវាកម្ម ដែលទាក់ទងនឹងសុវត្ថិភាពកុមារនៅក្នុងវិស័យសំខាន់ៗ ដូចជាការអប់រំ សណ្ឋាគារ ភោជនីយដ្ឋាន និងវិស័យផ្សេងៗជាច្រើនទៀត។

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖

-លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញផ្តល់កិច្ចសម្ភាសន៍ និងផ្តល់អនុសាសន៍ដល់ អង្គការ IOM ក្នុងការសិក្សាវាយតម្លៃ ប្រសិទ្ធភាពការអនុវត្តគម្រោង «ការគាំទ្រគោលនយោបាយ និងកម្មវិធីផ្អែកលើភស្តុតាងក្នុងបរិបទ នៃការចល័តឆ្លងកាត់ព្រំដែន ប្រទេសកម្ពុជា និងវៀតណាម»។

-លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញផ្តល់បទកិច្ចសម្ភាសន៍ជូន ស្ថានីយទូរទស្សន៍បាយ័ន ស្តីពីសារអប់រំផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹងបន្ថែមពីល្បិចកលនៃការឆបោក និងការកេងប្រវ័ញ្ចលើស្ត្រី និងក្មេងស្រី ពាក់ព័ន្ធអំពើជួញដូរមនុស្ស ក្នុងឱកាស ទិវានារីអន្តរជាតិខួបលើកទី១១៥ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ។

▪ ខេត្តសៀមរាប៖

-ស្នងការរងទទួលផែនការងារអន្តោប្រវេសន៍ នៃស្នងការដ្ឋាននគរបាលខេត្ត បានអញ្ជើញចូលរួមជាវាគ្មិនស្តីពីការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាអនឡាញ (ONLINE SCAMS) ចំនួន ១លើក។

-នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត និងអង្គការមូលនិធិអេ២១ បានអញ្ជើញចូលរួមជាវាគ្មិន ស្តីពីការចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងសម័យបច្ចេកវិទ្យា ចំនួន ០២លើក។

-នាយរងការិយាល័យកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល បានអញ្ជើញចូលរួមជាវាគ្មិន ស្តីពី វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពខេត្តសៀមរាបក្នុងឆ្នាំ២០២៥ និងផែនការបន្តឆ្នាំ២០២៦ ចំនួន ១លើក។

-តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រធានមជ្ឈមណ្ឌលការងារខេត្ត បានអញ្ជើញចូលរួមជាវាគ្មិនស្តីពី ការលើកកម្ពស់មុខរបរ និងការផ្តល់ឱកាសការងារដល់ពលករចំណាកស្រុកត្រលប់មកពីប្រទេសថៃ បានចំនួន ០១លើក។

▪ **ខេត្តព្រៃវែង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិនធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាលស្តីពី "យន្តការទទួលពាក្យបណ្តឹងសម្រាប់ពលករទេសន្តរប្រវេសន៍" ០១លើក រៀបចំដោយមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ខេត្តព្រៃវែង មានអ្នកចូលរួមសរុប ៣៧នាក់ ស្រី២៥នាក់។

### ក.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

#### ក.៣.១.ការធ្វើអធិការកិច្ចការងារ

▪ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអធិការកិច្ចការងារសរុបចំនួន ១៩២លើក ក្នុងនោះ វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូបចំនួន ១៣៨ និងវិស័យក្រៅកាត់ដេរ ផលិតស្បែកជើង ផលិតផលិតផលធ្វើដំណើរនិងកាបូបចំនួន ៥៤។

#### ក.៣.២. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសន៍ជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់សរុបចំនួន ៥៨៦នាក់ ស្រី ២៣នាក់ មាន២៩សញ្ជាតិ(កូរ៉េខាងត្បូង១០៤ ស្រី០៧, អាមេរិក៤៩ ស្រី០៥, ចិន៣៣៥ ស្រី០២, អូស្ត្រាលី១៥ ស្រី០៤, កាណាដា០៩, បារាំង១៧, អ៊ីតាលី០១, មីយ៉ាន់ម៉ា០៤ ស្រី០១, ស៊ុយអែត០១, អាល្លឺម៉ង់០៥, អាហ្វ្រិកខាងត្បូង០២នាក់ ស្រី០១, ម៉ាឡេស៊ី១៣ ស្រី០១, ហ្វីលីពីន០២, វៀតណាម០៤ ស្រី០១, ឥណ្ឌា០១, អង់គ្លេស០៥, ណូវែលសេឡង់០២ ស្រី០១, ន័រវេស០១, ស្លូវ៉ាគី០២, ឥណ្ឌូនេស៊ី០២, ជប៉ុន០៣, ស្រីលង្កា០១, ទួគី០១, នេប៉ាល់០១, អៀរឡង់០២, ឆែក០១, ដាណឺម៉ាក០១, ប៉ាគីស្ថាន០១, ហូឡង់០១។ *និងវាយតម្លៃបញ្ជូនទៅក្រុមការងារចម្រុះច្រកចេញ-ចូលតែមួយចំនួន៦៥៦នាក់ ស្រី២៣នាក់។*

#### ក.៣.៣. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

• **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស ទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ទំនាក់ទំនង ទិន្នន័យពលរដ្ឋខ្មែរធ្វើចំណាកស្រុកចេញទៅធ្វើការទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងពីអាណាព្យាបាល និងក្រុមគ្រួសារ ទាំង២៥ រាជធានី-ខេត្ត សរុប៤០,១៩៥នាក់ ស្រី ១,៨០៧៨នាក់ អនីតិជន៣២០នាក់ ស្រី១១៥នាក់ (ស្របច្បាប់ចំនួន៣៤,៦១២នាក់ ស្រី១៥,៥៥៣នាក់ អនីតិជន១៥៩នាក់ ស្រី៤៩នាក់ មិនស្របច្បាប់ចំនួន៥,៤៣៦នាក់ ស្រី២,៤៧៩នាក់ អនីតិជន១៣៤នាក់ ស្រី៥៥នាក់ ដាច់ការទាក់ទងចំនួន១៤៧នាក់ ស្រី៤៦នាក់ អនីតិជន២៧នាក់ ស្រី១១នាក់)។

➢ **ទិន្នន័យពលរដ្ឋខ្មែរមកពីក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់ទិន្នន័យពលរដ្ឋខ្មែរធ្វើ**ចំណាកស្រុកត្រឡប់ពីក្រៅប្រទេសវិញ ទាំងស្របច្បាប់ និងមិនស្របច្បាប់ ចំនួន១៤,៥០៨នាក់ ស្រី៦,៨៣៩នាក់ អនីតិជន៣៨១នាក់ ស្រី១៣២នាក់។

▪ **លេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ៖** បានធ្វើស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងបានវិលត្រឡប់មកវិញ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | រាជធានី ខេត្ត | ចំនួនពលរដ្ឋចំណាកស្រុកទៅក្រៅប្រទេស | | | | ចំនួនពលរដ្ឋវិលត្រឡប់ពីក្រៅប្រទេស | | | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួនពលរដ្ឋ | | អនីតិជន | | ចំនួនពលរដ្ឋ | | អនីតិជន | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | កណ្តាល | ៦,៣៩០ | ៣,៣៨៩ | ៦៦ | ១៨ | ១,៣៣៤ | ៤៥៣ | ៤១ | ២២ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២ | បាត់ដំបង | ៧០១ | ៣៣០ | | | | | | |
| ៣ | សៀមរាប | ២២,២៦២ | ១០,២៤៩ | ១,១៦០ | ៥៦៦ | ៩៦០ | ៤៥០ | ១១៩ | ៦៨ |
| ៤ | កំពង់ឆ្នាំង | ៨៣ | ៣២ | | | ១០១ | ២៧ | | |
| ៥ | កំពង់ចាម | ១២,៨១២ | ៥,៨៨៩ | | | ៧,៥២០ | ៣,៨២០ | ១៤២ | ៨៨ |
| ៦ | ព្រះសីហនុ | ២៥ | ១២ | | | | | | |
| ៧ | ព្រះវិហារ | | | | | ៦៧៤ | ៣០១ | ៦៣ | ៥២ |
| ៨ | ស្វាយរៀង | ៤,៩៩៣ | ២,៦៥៥ | | | ៤,០៥៩ | ១,៦៥៤ | | |
| ៩ | កោះកុង | ១,២២០ | ៦០៧ | ៩០ | ៣៥ | | | | |
| ១០ | ក្រចេះ | ១,៨៥១ | ៨៣៣ | | | ២,០៥៨ | ៨៨៩ | ៨៧ | ៣៥ |
| ១១ | កែប | ២១៦ | ១១៩ | | | ១៤១ | ៧១ | | |
| ១២ | កំពង់ស្ពឺ | ៩៣៣ | ១៦៨ | | | ០៦ | ០៤ | | |
| ១៣ | ស្ទឹងត្រែង | ៥៩៤ | ៣១១ | ១១ | ០៧ | | | | |
| ១៥ | ព្រៃវែង | ៣២៧ | ៦៦ | | | ៥៥៣ | ១៨០ | ១៣ | ០៧ |
| ១៦ | ត្បូងឃ្មុំ | ១២,៥៨៣ | ៥,៤៦៥ | ៧២ | ៣៩ | | | | |
| ១៧ | មណ្ឌលគិរី | ៨០ | ២៨ | ១៣ | ០៥ | | | | |
| ១៨ | តាកែវ | | | | | ៥,១៨៧ | ២,៦២២ | | |
| ១៩ | ពោធិ៍សាត់ | ១,០៦១ | ៥៥៦ | ៣៨ | ១២ | ១៨៤ | ៧១ | | |
| ២០ | ប៉ៃលិន | | | | | ២១ | ០៩ | ០៥ | ០២ |
| ២១ | ឧត្តរមានជ័យ | ៩,១៧៦ | ៤,៦៨៩ | ០២ | | | | | |
| | សរុបរួម | ៧៥,២០៧ | ៣៥,៣៩៨ | ១,៤៥២ | ៦៨២ | ២២,៧៩៨ | ១០,៥៥១ | ៤៧០ | ២៧៤ |

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

- **ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន**

| ខេត្ត | ច្រកទ្វារព្រំដែន | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី | អនីតិជន(ស្រី) |
|---|---|---|---|---|---|
| បាត់ដំបង | ថៃ | ២៦ | ៣,១១៦ | ១,១៨២ | ២១០ |
| កោះកុង | ថៃ | ១៣ | ៨០ | ១៩ | ០១ |
| ស្វាយរៀង | វៀតណាម | ០១ | ០៤ | ០៣ | |
| សរុបរួម | | ៤០លើក | ៣,២០០នាក់ | ១,២០៤នាក់ | ២១១នាក់ |

- **ការទទួលពលករនៅតាមមណ្ឌលទទួលពលករ**

▪ មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត បានទទួលពលករខ្មែរចំណាកស្រុកដែលត្រូវអាជ្ញាធរថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ សរុបចំនួន ៤២៥នាក់ (ប្រុស២៣៥នាក់ ស្រី១៤៣នាក់ កុមារា ២២នាក់ កុមារី២៥នាក់)។

▪ មណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង បានទទួលពលករខ្មែរបញ្ជូនត្រលប់ពីអាជ្ញាធរថៃ សរុបចំនួន ៨,០៦៤នាក់ ក្នុងនោះស្ត្រី ៣,៣១៦នាក់ (ស្ត្រីមានកូនតូចមកជាមួយ ៦៦១នាក់ និងស្ត្រីមានផ្ទៃពោះ ១០៨នាក់) អនីតិជន ៤៦៧នាក់ (អនីតិជនស្រី ២២១នាក់) និងជនមានពិការភាព ២៣នាក់(ស្ត្រី ៧នាក់)។

**គ.៤. ការបញ្ជូន និងទទួលពលករទេសន្តរប្រវេសន៍ដោយស្របច្បាប់**

▪ ក្រុមការងារទេសន្តរប្រវេសន៍ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនពលករទេសន្តរប្រវេសន៍ទៅធ្វើការនៅបរទេសដោយស្របច្បាប់ តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងតាមរយៈប្រព័ន្ធអនុគ្រោះមុខរបរ (EPS=Employment Permit System) របស់រាជរដ្ឋាភិបាល ដូចមានក្នុងតារាងខាងក្រោម៖

ទិន្នន័យបញ្ជូនពលករទេសន្តរប្រវេសន៍ខ្មែរទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់

| ល.រ | ប្រទេសគោលដៅ | ចំនួនរួម | ស្រី |
|---|---|---|---|
| ១ | សាធារណរដ្ឋកូរ៉េ | ៨២៦ | ២៧១ |
| ២ | ជប៉ុន | ១,៤៨០ | ៦២២ |
| ៣ | សិង្ហបុរី | ០៩ | ០៩ |
| ៤ | អ៊ីស្រាអែល | ៣៧ | ០៩ |
| | សរុប | ២,៣៥២នាក់ | ៩១១នាក់ |

**ក.៥. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

❖ការផ្សព្វផ្សាយ

▪ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ បានប្រារព្ធពិធីបើកយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការនិងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងលើកកម្ពស់លក្ខខណ្ឌការងារសម្រាប់កម្មករនិយោជិតវ័យក្មេងនៅតាមសហគ្រាស ឆ្នាំ២០២៦ នៅខេត្តក្រចេះ ដែលមានអ្នកចូលរួមសរុបចំនួន ៥០០នាក់ (ស្រី ១២៦នាក់)។

❖**អធិការកិច្ច**

▪ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ បានត្រួតពិនិត្យវាយតម្លៃលក្ខខណ្ឌការងារ និងប្រភេទការងារសម្រាប់កម្មករនិយោជិតវ័យក្មេង ដែលធ្វើការងារជាក់ស្តែងចំនួន ៤សហគ្រាស ដែលមានកម្មករនិយោជិតវ័យក្មេងសរុបចំនួន ៣៧នាក់ (ស្រី ១៨នាក់)។

**ក.៦. ការលើកកម្ពស់ជីវភាព**

❖ការផ្តល់ព័ត៌មានការងារ និងបង្កើនកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ

▪ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖

- បានផ្តល់ការណែនាំតម្រង់ទិសពលករមុនចេញដំណើរទៅធ្វើការនៅបរទេសចំនួន ១១លើក ដែលមានពលករសរុបចំនួន ៧២០នាក់ ស្រី ៤៣៣នាក់

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានអំពីឱកាសការងារ និងឱកាសកម្មសិក្សាការងារពីគ្រប់ប្រភពចំនួន ១៥៤,៩៧៣កន្លែង

- បានរៀបចំពិព័រណ៍ចល័តតាមរយៈមជ្ឈមណ្ឌលការងារដែលមានស្រាប់ និងមជ្ឈមណ្ឌលការងារចល័តនៅតាមមូលដ្ឋាន ទីប្រជុំជន និងគ្រឹះស្ថានសិក្សាចំនួន ៣២០ដង ដែលមានអ្នកចូលរួមសរុបចំនួន ២០,៣៩៤នាក់ ស្រី ១០,៨១២នាក់

- បានរៀបចំវេទិកាការងារ កម្មសិក្សាការងារ និងកិច្ចសម្ភាសន៍ការងារប្រចាំសប្តាហ៍ចំនួន ៥៤ដង ដែលមានអ្នកចូលរួមសរុបចំនួន ១៩,៣២៩នាក់ ស្រី ១០,៣៣១នាក់

- បានផ្តល់សេវាប្រឹក្សាយោបល់ អាជីព ការងារ និងវិជ្ជាជីវៈ ដល់សិស្ស និស្សិត និងអ្នកស្វែងរកការងារធ្វើសរុបចំនួន ២៦,១៥៤នាក់ ស្រី ១៤,៥០២នាក់

- បានផ្សព្វផ្សាយការធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាព (Recognition of Prior Learning-RPL) ដើម្បីផ្តល់វិញ្ញាបនប័ត្របញ្ជាក់កម្រិតសមត្ថភាពដោយឥតគិតថ្លៃលើជំនាញការងារផ្នែកសំណង់ ដល់បងប្អូនកម្មករនិយោជិតជាអតីតពលករខ្មែរ និងអ្នកមានបទពិសោធន៍ការងារ ប៉ុន្តែមិនទាន់មានលិខិតបញ្ជាក់ជំនាញសម្រាប់យកទៅប្រើប្រាស់ក្នុងការស្វែងរកឱកាសការងារថ្មី និងទទួលបានប្រាក់ចំណូលសមរម្យតាមកម្រិតជំនាញ

- តាមរយៈកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដល់យុវជន មកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ (កម្មវិធី TVET 1.5M) ដែលមានសិស្សបញ្ចប់ការសិក្សាសរុបចំនួន ៨៥,៤០៣នាក់ (មានប័ណ្ណសមធម៌ ឬប័ណ្ណងាយរងហានិភ័យសរុបចំនួន ៤២,០៨៥នាក់) និងកំពុងសិក្សាសរុបចំនួន ១៦,៧៣៦នាក់ (មានប័ណ្ណសមធម៌ ឬប័ណ្ណងាយរងហានិភ័យចំនួន ៨,៦៣០នាក់)។

▪ ខេត្តសៀមរាបៈ

-មជ្ឈមណ្ឌលការងារខេត្តសៀមរាប បានប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្មពីគ្រប់ប្រភព បានចំនួន៤៨៤កន្លែង។ បានរៀបចំពិព័រណ៍ការងារចល័ត និងវេទិកាការងារ បានចំនួន ៩លើក ដែលមានអ្នកចូលរួម សរុប ៧,៦០១នាក់ ស្រី ៤,១១៣នាក់។ បានទទួលចុះឈ្មោះអ្នកស្វែងរកការងារធ្វើ បានចំនួន ១,១០៧នាក់ ស្រី ៥៤៩នាក់ (ពលករ ៩៣៧នាក់ ស្រី៤៨៨នាក់) ។ បានផ្ដល់និងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជក បានចំនួន ២,៨៦៥នាក់ ស្រី ៧៨៩នាក់ (ពលករ ២,៤៩៤នាក់ ស្រី៦២៧នាក់)។ អ្នកទទួលបានការងារធ្វើសរុប ៩៤៨នាក់ ស្រី ៤០៦នាក់ (ពលករ ៨៥៨នាក់ ស្រី ៣៦០នាក់)។ ផ្ដល់ការប្រឹក្សាយោបល់អំពីអាជីព ការងារ និង វិជ្ជាជីវៈទៅអ្នកស្វែងរកការងារធ្វើ បានចំនួន ៩៧៩នាក់ ស្រី ៤៦៣នាក់។ អ្នកទទួលបានកម្មសិក្សាចំនួន ០៤នាក់ ស្រី ០២នាក់។

-មន្ទីរឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្ត បានជំរុញ និងលើកទឹកចិត្តដល់ សហគ្រិន ដោយបានណែនាំពីចំណុចដែលត្រូវកែលម្អនិងចំណុចត្រូវធ្វើបន្ថែមទៀត ដើម្បីផលិតកម្មមានដំណើរការ និងបានជួយកម្មករឱ្យមានការងារធ្វើនៅនឹងកន្លែង នៅក្នុងកម្មវិធីចុះអធិការកិច្ចតាមដាននៅតាមមូលដ្ឋានអាជីវកម្ម ន បានចំនួន ៥៣មូលដ្ឋាន សរុប ៣៦៦នាក់ ស្រី ១៩៣នាក់។

-អង្គការកល្យាណមិត្ត (Friend International) បានស្វែងរកការងារ និងគាំទ្រអតិថិជនឱ្យមាន ការងារ និងមុខរបរសរុប ចំនួន ៥៦នាក់ ស្រី ៣៩នាក់ ដោយក្នុងនោះ មានអតិថិជនបានដាក់ឱ្យមានការងារធ្វើ សរុបចំនួន ៣១នាក់ ស្រី ២១នាក់ និងអតិថិជនសរុបចំនួន ២៥នាក់ ស្រី ១៨នាក់ បានដាក់ជាមុខរបរអាជីវកម្ម ខ្នាតតូច។

▪ ខេត្តកំពង់ចាមៈ ក្រុមការងារទេសន្តរប្រវេសន៍ នៃមន្ទីរការងារ សហការ ជាមួយអង្គការភ្នំស្រីដើម្បី អភិវឌ្ឍន៍ និងវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម ចុះផ្សព្វផ្សាយពីការស្វែងរកការងារធ្វើក្នុងស្រុក និងវគ្គបណ្ដុះ បណ្ដាលបច្ចេកទេសនៅភូមិសំបូ ឃុំសូភាស ស្រុកស្ទឹងត្រង់ និង ឃុំខ្វិតធំ ស្រុកព្រៃឈរ អ្នកចូលរួម ២៤៥នាក់ ស្រី១៥៧នាក់។

▪ ខេត្តព្រៃវែងៈ ពលករវិលត្រឡប់ពីប្រទេសថៃ មានចំនួន ២២,១៨៩នាក់ ស្រី ៩,៥៧៥នាក់ ក្នុង នោះទទួលបានការងារធ្វើចំនួន ១៨,៥២១នាក់ ស្រី ៨,០៣០នាក់។

▪ ខេត្តពោធិ៍សាត់ៈ ពលករដែលត្រឡប់មកពីប្រទេសថៃសរុប ១០,១៥០នាក់ ស្រី ៤,៦៤៤នាក់។ ពលករដែលត្រឡប់មកពីប្រទេសថៃទទួលបានការងារធ្វើមានចំនួន ៤,៩៩៧នាក់ ស្រី ២,៣២២នាក់។

▪ ខេត្តកែបៈ បានផ្សព្វផ្សាយឱកាសការងារជូនដល់ប្រជាពលរដ្ឋនៅរដ្ឋបាលឃុំ សង្កាត់ទូទាំងខេត្ត ចំនួន ២លើក។ បានផ្សព្វផ្សាយឱកាសការងារក្នុងខេត្ត តាមរយៈផេកផ្លូវការរបស់មន្ទីរការងារ និងបណ្ដុះបណ្ដាល វិជ្ជាជីវៈក្នុងមួយសប្ដាហ៍ម្ដង និងបានរកការងារធ្វើជូនប្រជាពលរដ្ឋដែលបានត្រឡប់មកពីប្រទេសថៃចំនួន១០៥នាក់ ស្រី ៤៩នាក់។

▪ អង្គការអន្តរជាតិខាងការងារ (ILO)

-បានគាំទ្រទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ដើម្បីផ្ដល់ប្រឹក្សាអំពីព័ត៌មានការងារ និង ឱកាសការងារតាមរយៈមជ្ឈមណ្ឌលការងារនិងមជ្ឈមណ្ឌលការងារចល័ត ដល់ពលករទេសន្តរប្រវេសន៍ ជាពិសេស ពលករដែលវិលមកពីប្រទេសថៃ នៅខេត្តគោលដៅចំនួន ៥ គឺខេត្តកោះកុង បន្ទាយមានជ័យ តាកែវ សៀមរាប និង ខេត្តកំពង់ស្ពឺ។ បន្ថែមពីនេះក៏មានរៀបចំពិព័រណ៍ការងារនៅថ្នាក់ឃុំដើម្បីផ្ដល់ និងផ្ដល់ឱកាសការងារដល់ពួកគាត់

-តាមរយៈដៃគូអនុវត្តសកម្មភាព អង្គការ ILO បានគាំទ្រមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ ក្នុងការផ្ដល់ប្រឹក្សាយោបល់ បញ្ជូនពលករទៅទទួលវគ្គបណ្ដុះបណ្ដាលជំនាញខ្លី និងស្វែងរកការងារ ដល់ពលករ ទេសន្តរប្រវេសន៍ដែលបានវិលត្រឡប់មកវិញសរុបចំនួន ១១៧នាក់ ស្រី ៤៨នាក់។

❖ ការបើកវគ្គបណ្តុះបណ្តាលជំនាញបំណិនជីវិត

▪ រាជធានី-ខេត្ត មន្ទីរ អង្គភាព និងអង្គការដៃគូពាក់ព័ន្ធ៖ បានបើកវគ្គបណ្តុះបណ្តាលជំនាញបំណិនជីវិត ផ្នែកជួសជុលម៉ូតូ ជួសជុលគ្រឿងយន្តកសិកម្ម អ៊ុតសក់ ផាត់មុខ កុំព្យូទ័រ រដ្ឋបាល ភាសាអង់គ្លេស បច្ចេកទេសដាំដំណាំ បណ្តុះផ្សិត ដាំបន្លែ ការកែច្នៃផលិតផល ធ្វើជីកំប៉ុស្តិ៍ បច្ចេកទេសចិញ្ចឹមត្រី-មាន់-ជ្រូក បច្ចេកទេសបណ្តុះកូនឈើ បច្ចេកទេសជួសជុលអណ្តូងស្នប់ និងជំនាញផ្សេងៗ ដល់ប្រជាពលរដ្ឋក្រីក្រក្នុងសហគមន៍ ស្ត្រីមេម៉ាយ ក្មេងបោះបង់ការសិក្សា ដើម្បីលើកកម្ពស់ជីវភាព និងកាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន បានចំនួន ១៣វគ្គ អ្នកទទួលបានសេវា ចំនួន ៣៣៤នាក់ ស្រី ២៨៦នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាពថ្នាក់ក្រោមជាតិ | ចំនួនវគ្គ | អ្នកទទួលសេវា | ស្ត្រី |
|---|---|---|---|---|
| ១ | ខេត្តសៀមរាប(អង្គការកល្យាណមិត្ត) | ០៤ | ៣៦ | ២៤ |
| ២ | ខេត្តតាកែវ | ០២ | ៥៧ | ៤៦ |
| ៣ | ខេត្តកំពង់ឆ្នាំង | ០១ | ៩៥ | ៩៥ |
| ៥ | ខេត្តកំពង់ចាម | ០៣ | ១១០ | ១១០ |
| ៦ | ខេត្តកណ្តាល | ០៣ | ៣៦ | ១១ |
| សរុប | | ១៣ វគ្គ | ៣៣៤ នាក់ | ២៨៦ នាក់ |

### ក.៧. ការសិក្សាស្រាវជ្រាវ

▪ ខេត្តកណ្តាល៖ ក្រុមការងារក្រុងសំពៅពូនបានចុះសិក្សាស្រាវជ្រាវ អំពីទិន្នន័យកុមារ ដែលត្រូវឪពុកម្តាយធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្នុង និងក្រៅប្រទេស និងការស្វែងរកផលប៉ះពាល់របស់កុមារទាំងនោះក្នុងសង្កាត់ទាំង៥។

## ខ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ខ.១. ការងារអនុវត្តច្បាប់

❖ ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ៥០ករណី៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ចំនួន ៧២នាក់ ស្រី១១នាក់ ជនបរទេស ១១នាក់ ស្រី ០១នាក់ (ជនជាតិចិន)។
- សង្គ្រោះជនរងគ្រោះចំនួន ១៩៨នាក់ ស្រី ១០៤នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ ២៧នាក់ ស្រី ២៥នាក់ អាយុ១៥-១៧ឆ្នាំ ២៧នាក់ ស្រី ២២នាក់ និងអាយុ១៨ឆ្នាំឡើង ១៤៤នាក់ ស្រី ៥៧នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ១១៨នាក់ គ្រួសារ ៨០នាក់)។

ក្នុងនោះបែកជា៖

+ ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ២២ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ២៦នាក់ ស្រី០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១២១នាក់ ស្រី៣៣នាក់ មានអាយុក្រោម១៥ឆ្នាំ ០៣នាក់ ស្រី ០៣នាក់ អាយុ១៥-១៧ឆ្នាំ ០៨នាក់ ស្រី០៣នាក់ និងអាយុ១៨ឆ្នាំឡើង ១០៨នាក់ ស្រី២៧នាក់ (បញ្ជូនទៅសង្គមកិច្ច ៦១នាក់ គ្រួសារ ៦០នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ(ស្រី) |
|---|---|---|---|---|
| អំពើនាំឆ្លងដែន | ០១ | ០១ | | ០២ |
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១៦ | ១៩ | | ៥២(២៦) |
| អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០១ | ០១ | | ០១(០១) |
| ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០៤ | ០៥ | | ៦៦(០៦) |
| *សរុប* | *២២* | *២៦* | *០០* | *១២១(៣៣)* |

- **ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ២៨ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ៤៦នាក់ ស្រី១០នាក់ ជនជាតិចិន ១១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៧៧នាក់ ស្រី៧១នាក់ មានអាយុក្រោម១៥ឆ្នាំ ២២នាក់(ស្រី) អាយុ១៥-១៧ឆ្នាំ ១៩នាក់(ស្រី) និងអាយុ១៨ឆ្នាំឡើង ៣៦នាក់ ស្រី៣០នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៥៧នាក់ គ្រួសារ ២០នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ(ស្រី) |
|---|---|---|---|---|
| ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០២ | ០៨ | ចិន៤ | ០៧(០១) |
| សញ្ចារកម្ម | ០១ | ០៤ | ចិន៤ | ០៣(០៣) |
| សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០៥ | ១០ | ចិន៣ | ៤០(៤០) |
| ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០១ | ០៥ | | ០៨(០៨) |
| រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០១ | | ០១(០១) |
| រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០២ | ០២ | | ០២(០២) |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៥ | ១៥ | | ១៥(១៥) |
| អំពើអាសប្រទាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | | ០១(០១) |
| *សរុប* | *២៨* | *៤៦* | *១១* | *៧៧(៧១)* |

### ខ.២. កិច្ចការយុត្តិធម៌

- **លទ្ធផលចំណាត់ការផ្តន្ទាទោស**

ក្រុមការងារកិច្ចការយុត្តិធម៌ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងយុត្តិធម៌ ទិន្នន័យទទួលបានពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជាលទ្ធផលតាមដំណាក់កាលទាំង៣ នៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

**១. ដំណាក់កាលអយ្យការ-បទល្មើសជួញដូរមនុស្ស**

- សំណុំរឿងសរុបចំនួន ១៧៩ ក្នុងនោះ(សំណុំរឿងចាស់ ២៧ និងសំណុំរឿងថ្មី ១៥២)
- សំណុំរឿងឃាត់ខ្លួន ១៦១
- សំណុំរឿងមិនឃាត់ខ្លួន ៣៥
- សំណុំរឿងចាត់ការរួច ១៤៣សំណុំរឿង(ថ្មី ១២២)៖

-បើកការស៊ើបសួរ ១២២ តម្កល់រឿងទុកឥតចាត់ការ១៥ បង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម០២ បញ្ជូនទៅជំនុំជម្រះផ្ទាល់០១ ផ្ទេរសមត្ថកិច្ច០២ និងបញ្ចូលសំណុំរឿង០១

- សំណុំរឿងនៅសល់កំពុងចាត់ការ ៣២សំណុំរឿង(ថ្មី ២៨)

➢ ជនសង្ស័យ សរុបចំនួន ៥០២នាក់(ស្រី ៥០នាក់) ក្នុងនោះ៖ នីតិជន ២៩៩នាក់(ស្រី៤៣នាក់) អនីតិជន ២០នាក់(ស្រី០១នាក់) ជនបរទេស ១៣៩នាក់(ស្រី០៦នាក់)។

➢ ជនរងគ្រោះ សរុបចំនួន ២៩៣នាក់(ស្រី១០៨នាក់) ក្នុងនោះ៖ នីតិជន៩៨នាក់(ស្រី៣១នាក់) អនីតិជន ១០០នាក់(ស្រី៧២នាក់) និងជនបរទេស ៩៥នាក់(ស្រី០៥នាក់)។

## ២. ដំណាក់កាលស៊ើបសួរ-បទល្មើសជួញដូរមនុស្ស

➢ សំណុំរឿងសរុបចំនួន ៣០៤ ក្នុងនោះ(សំណុំរឿងចាសើ ១៥១ និងសំណុំរឿងថ្មី ១៥៣)៖

➢ សម្រេចឃុំខ្លួនបណ្ដោះអាសន្ន ៤០៣នាក់

➢ សម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ១២នាក់

➢ សម្រេចឱ្យនៅក្រៅឃុំ ០៩នាក់

➢ ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ០៧នាក់

➢ សំណុំរឿងចាត់ការរួច ១១២សំណុំរឿង(ថ្មី ១៩)

-បញ្ជូនទៅជំនុំជម្រះ ១០៩សំណុំរឿង(ថ្មី ១៩) និងលើកលែងចោទប្រកាន់ ០៣សំណុំរឿង។

➢ បញ្ចូលសំណុំរឿង ០៤

➢ សំណុំរឿងនៅសល់កំពុងចាត់ការ ១៦៥សំណុំរឿង(ថ្មី ១០៨)

➢ ជនត្រូវចោទសរុបចំនួន ៧៧៦នាក់(ស្រី៧៧នាក់) ក្នុងនោះ នីតិជន ៥២១នាក់(ស្រី ៥៧នាក់) អនីតិជន ៤៣នាក់(ស្រី០៧នាក់) និងជនបរទេស ២១២នាក់(ស្រី១៣នាក់)

➢ ជនរងគ្រោះសរុបចំនួន ៣១៣នាក់(ស្រី ១៧៥នាក់) ក្នុងនោះ នីតិជន ១៥០នាក់(ស្រី ៨១នាក់) អនីតិជន ១១១នាក់(ស្រី៩០នាក់) និងជនបរទេស ៥២នាក់(ស្រី ០៤នាក់)។

## ៣. ដំណាក់កាលជំនុំជម្រះ-បទល្មើសជួញដូរមនុស្ស

➢ សំណុំរឿងសរុបចំនួន ២៧៩ ក្នុងនោះ(សំណុំរឿងសល់ពីមុន ១៥១ និងសំណុំរឿងចូលថ្មី ១២៨)

➢ ជនរងគ្រោះសរុបមានចំនួន ៣១៨នាក់(ស្រី១៨៤នាក់) ក្នុងនោះ នីតិជន១៦២នាក់(ស្រី៦៨នាក់) អនីតិជន ១១៣នាក់(ស្រី) និងជនបរទេស ៤៣នាក់(ស្រី០៣នាក់)។

➢ ជនជាប់ចោទសរុបមានចំនួន ៤៩២នាក់(ស្រី៣៦នាក់) ក្នុងនោះនីតិជន ៣៣៣នាក់(ស្រី៣៣នាក់) អនីតិជន ៣៥នាក់ និងជនបរទេស ១២៤នាក់(ស្រី០៣នាក់)។

➢ សំណុំរឿងចាត់ការរួច៖

-បានជំនុំជម្រះ៖ ១១៤សំណុំរឿង(ថ្មី ៥៣) មនុស្ស ១៥៦នាក់ ស្រី១៥នាក់

-ចេញសាលក្រម៖ ៨១សំណុំរឿង(ថ្មី ២៥) មនុស្ស ១១៨នាក់ ស្រី១២នាក់

-រួចផុតបទចោទ៖ ០៧សំណុំរឿង(ថ្មី ០៤) មនុស្ស ០៦នាក់ ស្រី០៣នាក់

-ផ្ដន្ទាទោសដាក់ពន្ធនាគារ៖ ៧៣សំណុំរឿង(ថ្មី ២២) មនុស្ស ១០៥នាក់ ស្រី០៩នាក់

-ព្យួរទោស៖ ០៥សំណុំរឿង មនុស្ស ០៦នាក់

➢ សម្រេចផ្ដល់សំណងដល់ជនរងគ្រោះ៖ ១០សំណុំរឿង

➢ សរុបចំណាត់ការ(ចេញសាលក្រម)៖ ៨១សំណុំរឿង(ថ្មី ២៥)

➢ សំណុំរឿងសល់កំពុងចាត់ការ៖ ១៩៨សំណុំរឿង(ថ្មី១០៣)

➢ បណ្ដឹងឧបាស្រ័យ-បណ្ដឹងឧទ្ធរណ៍៖ ០៧សំណុំរឿង

## គ. កិច្ចការពារជនរងគ្រោះ

### គ.១. ការទទួល និងសម្ភាសពលករបញ្ជូនទាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

▪ ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងប្រទេស និងក្រៅប្រទេស ចំនួន ១៣៥នាក់(ប្រុស០២នាក់ ស្រី៧៨នាក់ កុមារី៥៥នាក់) ក្នុងនោះ៖

- ក្នុងប្រទេសចំនួន ៦៩នាក់ (ប្រុស០១នាក់ ស្រី២៤នាក់ កុមារី៤៤នាក់)
  - ខ្មែរ ៦៣នាក់(ស្រី២១នាក់ កុមារី៤២នាក់)ករណីរំលោភបំពានផ្លូវភេទ០១នាក់កុមារី, សញ្ចារកម្ម ៦២នាក់(ស្រី២១នាក់ កុមារី៤១នាក់)។
  - បរទេស ០៤នាក់(ប្រុស០១នាក់ ស្រី០៣នាក់ កុមារី០២នាក់) ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ០១នាក់ជនជាតិមីយ៉ាន់ម៉ា, សញ្ចារកម្ម០៤នាក់(ស្រី០៣ កុមារី០១) ជនជាតិឡាវ០៣នាក់ ចិន ០១នាក់ និងករណីងាយរងគ្រោះ០១នាក់កុមារី។
- ក្រៅប្រទេសចំនួន ៦៦នាក់(ប្រុស០១នាក់ ស្រី៥៤នាក់ កុមារី១១នាក់)
  - ប្រទេសចិន ៦១នាក់(ស្រី៥២នាក់ កុមារី០៩នាក់) ករណីរៀបអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ
  - ប្រទេសវៀតណាម ០៣នាក់(ស្រី០១នាក់ កុមារី០២នាក់) ករណីរៀបអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ
  - ប្រទេសម៉ាឡេស៊ី ០១នាក់ស្រី ករណីអាជីវកម្មផ្លូវភេទ។
  - ករណីងាយរងគ្រោះ ០១នាក់ប្រុស

➢ *ជនរងគ្រោះក្រោយពីទទួលបានការកំណត់អត្តសញ្ញាណពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញ ចំនួន ១៣៥នាក់(ប្រុស០២នាក់ ស្រី៧៨នាក់ កុមារី៥៥នាក់)។*

### គ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទា

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា និងទទួលសេវា នៅមជ្ឈមណ្ឌល របស់អង្គការដៃគូ ចំនួន ១៣៥នាក់(ប្រុស០២នាក់ ស្រី៧៨នាក់ កុមារី៥៥នាក់) ក្នុងនោះ៖ អង្គការការីតាស់កម្ពុជា៣១នាក់(ប្រុស២ ស្រី២៦ កុមារី៣), អង្គការរតនៈអ៊ីនធើណេសិនណល០៦នាក់(ស្រី៤នាក់ កុមារី២), អង្គការមូលនិធិហាការអន្តរជាតិ០៣នាក់(ស្រី២ កុមារី១), អង្គការសម្ព័ន្ធចាប់ដៃ០៩នាក់(ស្រី៧ កុមារី២), អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ២៣នាក់(ស្រី១៨ កុមារី៥), អង្គការអាហ្វេស៊ីប០១នាក់កុមារី និងមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៦២នាក់(ស្រី២១ កុមារី៤១)។

### គ.៤. ការធ្វើមាតុភូមិនិវត្តន៍

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ដែលត្រូវបាន ធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសដើមវិញ ចំនួន ១០នាក់(ប្រុស៤ ស្រី៥ កុមារី១) មានជនជាតិឡាវ៣នាក់ស្រី ចិន២ នាក់(ប្រុស១ ស្រី១) មីយ៉ាន់ម៉ា០១នាក់ប្រុស និងអាឡឺម៉ង់០១នាក់កុមារី។

### គ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ

បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ ត្រឡប់ទៅសហគមន៍ វិញចំនួន ៣៩នាក់(ប្រុស១ ស្រី១៩ កុមារា២ កុមារី១៧)។

### គ.៦. ការតាមដាន

បានតាមដានជនរងគ្រោះ ក្រោយពីធ្វើសមាហរណកម្មទៅសហគមន៍ ចំនួន ៦២១នាក់(ប្រុស១៤នាក់ ស្រី២៧៥នាក់ កុមារា៥៩នាក់ កុមារី២៧៣នាក់)។

### គ.៧. ការបិទករណី

បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០៦នាក់(ស្រី០៣នាក់ កុមារី០៣នាក់)។

**ឃ. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ**

▪ខេត្តក្រចេះ៖ បានរៀបចំកែសម្រួល និងផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តក្រចេះ(គ.ខ.ប.ជ) និងបានរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២៦។

▪ខេត្តកំពង់ចាម៖ បានរៀបចំកែសម្រួលលើផែនការសម្មភាព និងផែនការថវិកា នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត។

▪ខេត្តតាកែវ បានចេញសេចក្តីសម្រេចចំនួន ០២ច្បាប់ ក្នុងនោះសេចក្តីសម្រេចស្តីពីការតែងតាំង សមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត(គ.ខ.ប.ជ)លេខ ០៤៧/២៦ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦ និងចេញសម្រេចលេខ ០២១/២៦ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦ស្តីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ)។

## III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការបណ្តុះបណ្តាល

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បណ្តុះបណ្តាលពី៖<br>-បានពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចការងារនៃនាយកដ្ឋានការងារកុមារ ស្តីពីច្បាប់អនុសញ្ញាពាក់ព័ន្ធនឹងពលកម្មកុមារ នីតិវិធីនៃការចុះធ្វើអធិការកិច្ចការងារ និងនីតិវិធីនៃការស្នើសុំប្រើប្រាស់កម្មករនិយោជិតវ័យក្មេងចំនួន ១វគ្គ អ្នកចូលរួម ៣៩នាក់ ស្រី ១០នាក់។<br>-បានរៀបចំវគ្គពង្រឹងសមត្ថភាពគ្រូឧទ្ទេស ដើម្បីចុះផ្សព្វផ្សាយស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងលើកកម្ពស់លក្ខខណ្ឌការងារសម្រាប់កម្មករនិយោជិតវ័យក្មេង ឆ្នាំ២០២៦ តាមប្រព័ន្ធអនឡាញ (Zoom) ចំនួន ១វគ្គ មានអ្នកចូលរួម ៥០នាក់។ | ០២ | ៨៩ | ១០ |
| ២ | ក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយអង្គការ world hope international បណ្តុះបណ្តាលស្តីពី ផ្ទះមានសុវត្ថិភាព សុខមាលភាពដល់គ្រួសារប្រឆាំងទៅនឹងការរំលោភបំពាន់ និងកេងប្រវ័ញ្ចផ្លូវភេទ។ | ០២ | ១០១ | ៥៦ |
| ៣ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ ស្តីពីកិច្ចការកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ចំនួន ០២វគ្គ នៅខេត្តស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ ព្រះវិហារ មនុស្ស១៣៤នាក់ ស្រី៦៣នាក់ និងនៅខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ធំ ព្រៃវែង ស្វាយរៀង មនុស្ស ១៥៣នាក់ ស្រី៨១នាក់។ | ០២ | ២៨៧ | ១៤៤ |
| ៤ | ខេត្តសៀមរាប៖ ស្តីពី ការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទស្ត្រី កុមារ តាមប្រព័ន្ធអនឡាញ ១លើក មនុស្ស១១នាក់ ស្រី០៦នាក់។ សហកាជាមួយអង្គការទស្សនពិភពលោក បណ្តុះបណ្តាលស្តីពី យន្តការនៃការរាយការណ៍ និងការបញ្ជូននៅសហគមន៍ ១លើក មនុស្ស ៣៣នាក់ ស្រី២៩នាក់ និងបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណកម្មពលករទេសន្តរ ប្រវេសន៍ត្រឡប់ពីប្រទេសថៃ ១លើក។ សហការជាមួយ UNICEF បណ្តុះបណ្តាលស្តីពីច្បាប់យុត្តិធម៌អនីតិជន និងតួនាទីភារកិច្ចរបស់ភ្នាក់ងារសង្គមកិច្ច ១លើក មនុស្ស ១១៦នាក់ ស្រី៥៦នាក់។ | ០៤ | ១៦០ | ៩១ |

| | | | | |
|---|---|---|---|---|
| ៥ | ខេត្តកណ្តាល សហកាជាមួយអង្គការ APLE រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការ ទប់ស្កាត់ ឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើប្រព័ន្ធអនឡាញ។ | ០១ | ៣៧ | ១៣ |
| ៦ | ខេត្តក្រចេះ៖ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត សហការជាមួយ អង្គការទស្សនៈពិភពលោក បើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីប្រតិបត្តិការងារកិច្ច ការពារកុមារ ដើម្បីការពារកុមារពីការរំលោភបំពានគ្រប់ទម្រង់។ | ០១ | ៥០ | ៣០ |
| ៧ | ខេត្តស្ទឹងត្រែង៖ ស្នងការដ្ឋាននគរបាលខេត្តបើកវគ្គបណ្តុះបណ្តាលស្តីពីការកំណត់ អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ | ០១ | ៣០ | ១១ |
| | *សរុប* | *១៣វគ្គ* | *៧៥៤នាក់* | *៣៥នាក់* |

### ក.២. សិក្ខាសាលា

❖ សិក្ខាសាលាក្នុងប្រទេស

▪ ក្រសួងសង្គមកិច្ច៖ សហការជាមួយ គម្រោង JICA និង ASEAN-ACT រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ដាក់អនុវត្តសាកល្បងស្តីពី គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប ដែលបានកែសម្រួលរួច គម្រោងអភិវឌ្ឍសមត្ថភាពដើម្បីជួយដល់ ជនរងគ្រោះដែលរួចពីការជួញដូរមនុស្ស ចំនួន០៣លើក នៅខេត្តត្បូងឃ្មុំ១លើក អ្នកចូលរួម ៥៣នាក់ ស្រី១៩នាក់, ខេត្តស្វាយរៀង១លើក អ្នកចូលរួម ៥២នាក់ ស្រី២០នាក់ និងនៅខេត្តសៀមរាប១លើក អ្នកចូលរួម ៥៩នាក់ ស្រី ២៨នាក់។ បានសហការជាមួយគម្រោង JICA រៀបចំសិក្ខាសាលាតាមដានលើការប្រើប្រាស់ទម្រង់របាយការណ៍ស្តីពី ការផ្តល់សេវាគាំពារជនរងគ្រោះដោយអំពើធ្វើអាជីវកម្មផ្លូវភេទ ចំនួន០១លើក អ្នកចូលរួម៤៥នាក់ ស្រី២៥នាក់ នៅ សណ្ឋាគារកាំបូឌីយ៉ាណា ភ្នំពេញ។

▪ ខេត្តសៀមរាប៖ លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាល មន្ទីរកិច្ចការនារី មន្ទីរទេសចរណ៍ និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១៣ក្រុង-ស្រុក រៀបចំសិក្ខាសាលា តម្រង់ទិសលើសៀវភៅណែនាំ ស្តីពី នីតិវិធីប្រតិបត្តិកិច្ចការពារកុមារ សម្រាប់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ បានចំនួន ០១លើក នៅបន្ទប់ប្រជុំសាលា ខេត្តសៀមរាប ដែលមានអ្នកចូលរួមសរុប ៧៨នាក់ ស្រី៣៧នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

❖ **ការរៀបចំកិច្ចប្រជុំនៅក្នុងប្រទេស**

▪ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ រៀបចំកិច្ចប្រជុំ ១០លើក មនុស្ស ២១៤នាក់ ស្រី៦៤នាក់

-បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសលើកទី២ ជាមួយភាគីម៉ាឡេស៊ី ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ី ស្តីពីការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍ របស់ពលករទូទៅ និងពលករការងារផ្ទះ នៅខេត្តសៀមរាប

-បានរៀបចំកិច្ចប្រជុំពិភាក្សាលើកទី៣ លើសេចក្តីព្រាងអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ ស្តីពីប្រព័ន្ធការងារសម្រាប់ការអភិវឌ្ឍជំនាញ ( Employment for Skill Development Program) ជាមួយភាគីជប៉ុន តាមរយៈប្រព័ន្ធវីដេអូ

-បានរៀបចំកិច្ចប្រជុំក្រុមការងារទេសន្តរប្រវេសន៍ ដើម្បីពិនិត្យលើរបាយការណ៍លទ្ធផលការងារប្រចាំត្រីមាសទី១ សម្រាប់ឆ្នាំ២០២៦ និងទិសដៅអនុវត្តបន្តរបស់ក្រុមការងារទេសន្តរប្រវេសន៍នៃ គ.ជ.ប.ជ នៅទីស្តីការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់លើកទី២ នៃគម្រោងការពារសិទ្ធិស្ត្រី និងកុមារក្នុងបរិបទទេសន្តប្រវេសន៍ការងារ (PROTECT) ដើម្បីចែករំលែកអំពីវឌ្ឍនភាព និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តគម្រោងក្នុងអំឡុងឆ្នាំ២០២៤-២០២៥ និងពិភាក្សាលើការកំណត់ផែនការសកម្មភាពអាទិភាពសម្រាប់បន្តអនុវត្តក្នុងឆ្នាំ២០២៦

- បានរៀបចំកិច្ចប្រជុំណែនាំដល់ទីភ្នាក់ងារផ្តល់សេវាការងារក្រៅប្រទេស ដែលបានទទួលការអនុញ្ញាតពីក្រសួង ក្នុងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងជនទេសន្តប្រវេសន៍ការងារខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី និងប្រទេសសិង្ហបុរី ដើម្បីពន្លឿន និងពង្រឹងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងជនទេសន្តប្រវេសន៍ខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី និងប្រទេសសិង្ហបុរី នៅទីស្តីការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានរៀបចំកិច្ចប្រជុំណែនាំដល់ទីភ្នាក់ងារផ្តល់សេវាការងារក្រៅប្រទេសចំនួន ១០២ក្រុមហ៊ុន ដើម្បីពង្រឹងយន្តការបញ្ជូនជនទេសន្តប្រវេសន៍ការងារខ្មែរទៅធ្វើការនៅក្រៅប្រទេស និងបង្កើនការស្វែងរកទីផ្សារការងារដែលមានលក្ខខណ្ឌការងារល្អនៅបណ្តាប្រទេសអភិវឌ្ឍន៍ មានអ្នកចូលរួមសរុបចំនួន ១១៩នាក់ ស្រី ៣៤នាក់ នៅទីស្តីការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានរៀបចំកិច្ចប្រជុំអន្តរក្រសួងពិនិត្យ និងផ្តល់ធាតុចូលលើកម្រងសំណួរ របាយការណ៍ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមាររបស់ក្រសួងការងារសហរដ្ឋអាម៉េរិក ឆ្នាំ២០២៥ ចំនួន ២លើក ដែលមានអ្នកចូលរួមសរុបចំនួន ៩៥នាក់ ស្រី ៣០នាក់

- បានរៀបចំកិច្ចប្រជុំក្រុមការងារទេសន្តប្រវេសន៍ ដើម្បីពិនិត្យលើរបាយការណ៍លទ្ធផលការងារប្រចាំត្រីមាសទី១ សម្រាប់ឆ្នាំ២០២៦ និងទិសដៅអនុវត្តបន្តរបស់ក្រុមការងារទេសន្តប្រវេសន៍នៃ គ.ជ.ប.ជ នៅទីស្តីការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

▪ សមាគមទីភ្នាក់ងារជ្រើសរើសពលកម្មករកម្ពុជា (ACRA) បានរៀបចំកិច្ចប្រជុំជាមួយសមាជិកនៃសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា ស្តីពីការគ្រប់គ្រងលើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស និងការពិភាក្សាអំពីការបើកទីផ្សារថ្មី ដែលមានអ្នកចូលរួមសរុបចំនួន ៨៨នាក់ ស្រី ៣០នាក់ មកពីក្រុមហ៊ុនចំនួន ៧៩។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ រៀបចំកិច្ចប្រជុំ ២១លើក អ្នកចូលរួមសរុប៧៨៤នាក់ ស្រី២០៩នាក់៖**

- កិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងរបាយការណ៍ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ តាមប្រព័ន្ធអនឡាញ (Zoom meeting) ជាមួយក្រុមការងារលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ទាំង២៥ និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ៦០នាក់

- កិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន ត្រៀមរៀបចំកម្មវិធី ទិវាអន្តរជាតិសុវត្ថិភាពអ៊ីនធឺណេត ០១លើក អ្នកចូលរួម ២៤នាក់ ស្រី ០៦នាក់ និងកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាង អនុស្សរណៈនៃការយោគយល់ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលប្រេស៊ីល គោលបំណងដើម្បីកំណត់ការអនុវត្តកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលគ្នាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើរត់ពន្ធមនុស្ស ០១លើក អ្នកចូលរួម ២២នាក់ ស្រី០៤នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ

- កិច្ចប្រជុំកែសម្រួលសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ របស់អង្គភាពការពារកុមារ CPU ចំនួន ០១លើក អ្នកចូលរួម ០៧នាក់ ស្រី ០២នាក់

- កិច្ចប្រជុំផ្ទៃក្នុង ពិនិត្យវឌ្ឍនភាពការអនុវត្តការងារ ឆ្នាំ២០២៥ លើកទិសដៅអនុវត្ត ឆ្នាំ២០២៦ និងពង្រឹងការអនុវត្តវិន័យក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ០១លើក អ្នកចូលរួម ២៧នាក់ ស្រី ០៦នាក់។ កិច្ចប្រជុំពិនិត្យរបាយការណ៍ ក្រសួង ស្ថាប័ន ដើម្បីឆ្លើយតបរបាយការណ៍ GCM ០១លើក អ្នកចូលរួម ១៣នាក់ ស្រី ០៤នាក់ និងកិច្ចប្រជុំពិនិត្យ និងការផ្តល់ធាតុចូលលើកម្រងសំណួរ នៃរបាយការណ៍ ស្តីពីការរកឃើញទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ឆ្នាំ២០២៥ របស់ក្រសួងការងារ សហរដ្ឋអាម៉េរិក ០៤លើក អ្នកចូលរួម ២៨នាក់ ស្រី០៦នាក់

- កិច្ចជុំចង្អៀតអន្តរក្រសួង ស្ថាប័ន ដើម្បីពិនិត្យជាតុចូល សម្រាប់ការឆ្លើយតបទៅនឹងការត្រៀមរៀបចំរបាយការណ៍វាយតម្លៃរបស់ក្រសួងការបរទេសអាម៉េរិក ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ០១លើក អ្នកចូលរួម ៣១រូប ស្រី ០៧រូប នៅទីស្តីការក្រសួងមហាផ្ទៃ

- កិច្ចប្រជុំដើម្បីពិនិត្យការងារត្រៀមរៀបចំកម្មវិធី ទិវាជាតិប្រឆាំងការជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦ ចំនួន ០៣លើក អ្នកចូលរួម ១៨នាក់ ស្រី ០៣នាក់

- កិច្ចប្រជុំពិភាក្សាក្រុមការងារបច្ចេកទេស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយក្រុមការងារបច្ចេកទេសរបស់អង្គការយូនីសេហ្វ (UNICEF) ស្តីពីការបន្តផែនការសកម្មភាពឆ្នាំ២០២៦ នៃការប្រមូលទិន្នន័យកុមាររងគ្រោះ ដោយការធ្វើចំណាកស្រុក ក្នុងគ្រួសារទេសន្តប្រវេសន៍ ០២លើក អ្នកចូលរួម ០៦នាក់ ស្រី០១នាក់ នៅសាលប្រជុំ គ.ជ.ប.ជ

- ស្តីពីការត្រៀមរៀបចំផ្សព្វផ្សាយរបាយការណ៍ជាតិ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ ចំនួន ០១លើក អ្នកចូលរួម ០៧នាក់ ស្រី០៣នាក់

- កិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** មានអ្នកចូលរួមប្រមាណ ៥២០រូប ស្រី ១៦១រូប នៅទីស្តីការក្រសួងមហាផ្ទៃ។

- កិច្ចប្រជុំកម្រិតបច្ចេកទេស រៀបចំមេរៀនគោលសម្រាប់បណ្តុះបណ្តាលសៀវភៅ ស្តីពីក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨ ចំនួន ០៣លើក ជាមួយ តំណាងអង្គការ IJM និង ASEAN-ACT អ្នកចូលរួម ៣៤នាក់ ស្រី ០៦នាក់ នៅសាលប្រជុំ គ.ជ.ប.ជ។

▪ លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ៖ បានរៀបចំកិច្ចប្រជុំ បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែ និងត្រីមាសទី១ ឆ្នាំ២០២៦ ចំនួន ៤៦លើក មានអ្នកចូលរួមចំនួន ១,៥២១នាក់ ស្រី ៧៣១នាក់ ក្នុងនោះមានខេត្ត៖ ខេត្តសៀមរាប ៣៨លើក អ្នកចូលរួម១,២៧០នាក់ ស្រី៥៨០នាក់, កណ្តាល ០១លើក អ្នកចូលរួម ៧៤នាក់ ស្រី ៦៤នាក់, ព្រះវិហារ ០៣លើក អ្នកចូលរួម ៣៦នាក់ ស្រី ១៦នាក់, កំពង់ចាម ០១លើក អ្នកចូលរួម ៥៧នាក់ ស្រី៣៨នាក់, ខេត្តតាកែវ ០១លើក អ្នកចូលរួម ២៧នាក់ ស្រី ១១នាក់, កែប ០១លើក និងខេត្តស្វាយរៀង ០១លើក អ្នកចូលរួម ៥៧នាក់ ស្រី២៣នាក់។

❖ **ការចូលរួមកិច្ចប្រជុំនៅក្រៅប្រទេស**

▪ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) បានចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការលើកកម្ពស់ការការពារពលករទេសន្តប្រវេសន៍ពីអាស៊ី ទៅធ្វើការនៅប្រទេសជប៉ុន ដែលរៀបចំឡើងដោយអង្គការអន្តរជាតិខាងការងារ (ILO) តាមរយៈប្រព័ន្ធអនឡាញ។

### ខ.២. ទស្សនកិច្ច

▪ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ បានចូលរួមដំណើរទស្សនកិច្ចសិក្សាគម្រោងរបស់អង្គការស៊ីប៉ា គម្រោង អប់រំក្នុងសិប្បកម្មឡដុត នៅខេត្តកណ្តាល និងបានចូលរួមទស្សនកិច្ច និងធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណពលករទេសន្តប្រវេសន៍ត្រឡប់ពីប្រទេសថៃ នៅខេត្តកំពង់ចាម, កំពង់ធំ និងខេត្តកំពង់ស្ពឺ។

▪ ខេត្តសៀមរាប៖ ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានអមដំណើរលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចុះទស្សនៈកិច្ចនៅមណ្ឌលថែទាំកុមាររបស់អង្គការដៃកម្ពុជា (ARM) ចំនួន ០១លើក។ ក្រុមការងារស្រុកពួក បានសហការជាមួយមន្ទីរសង្គមកិច្ច និងអង្គការUNICEF ចុះពិនិត្យមើលស្ថង់កុមារមេត្រី ដែលដាក់នៅក្នុងមណ្ឌលជនភៀសសឹងនៅវត្តខ្នាត ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប។

## ខ.៣. ជំនួបពិភាក្សាការងារ

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍បានដឹកនាំក្រុមការងារអគ្គលេខាធិការដ្ឋាន ក្នុងជំនួបពិភាក្សាការងារ ជាមួយៈ

- នាយកអង្គការ IJM ប្រចាំតំបន់ពិភាក្សាការងារដើម្បីបន្តពង្រឹងកិច្ចសហការ ក្នុងភាពជាដៃគូអភិវឌ្ឍន៍ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ។

- តំណាងអង្គការ IOM ដើម្បីសហការសម្របសម្រួលដោះស្រាយករណី នៃការកើនឡើងសំណើសុំជំនួយពីចំនួនទេសន្តរប្រវេសន៍បរទេស ដែលមិនអាចវិលត្រឡប់ ទៅប្រទេសកំណើតវិញ។

- តំណាងស្ថានទូតអូស្ត្រាលី ទទួលបន្ទុកការងារប្រឆាំងទាសភាពសម័យទំនើប និងការជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ

- តំណាងអង្គការ កម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- តំណាងអង្គការ JICA អំពីលទ្ធផល នៃការអនុវត្តសាកល្បង លើការប្រើប្រាស់ គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលបានកែសម្រួលរួច នៅទីស្តីការក្រសួងមហាផ្ទៃ។

- លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានជួបពិភាក្សាការងារ ជាមួយតំណាងក្រសួងអប់រំ យុវជន និងកីឡា និងតំណាងអង្គការ APLE ស្តីពីការត្រៀមរៀបចំយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ិនធឺណិតឆ្នាំ២០២៦។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានជួបពិភាក្សាការងារជាមួយតំណាងអង្គការ SIPAR និងតំណាងសមាគមនារី សម្រាប់សន្តិភាព និងការអភិវឌ្ឍ (CWPD) អំពីកិច្ចសហការក្នុងការលើកកម្ពស់ការអប់រំដល់កុមារដែលរស់នៅជុំវិញបរិវេណសិប្បកម្មផលិតឥដ្ឋ។

▪ សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA)៖ បានជួបពិភាក្សាការងារជាមួយ លោក Park Namsoon នាយកមជ្ឈមណ្ឌលពលករទេសន្តរប្រវេសន៍មាតុភូមិនិវត្តន៍កម្ពុជា (HRCC) និងសហការី ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការក្នុងការជួយគាំទ្រ ដល់ជនទេសន្តរប្រវេសន៍ការងារខ្មែរដែលធ្វើមាតុភូមិនិវត្តន៍ តាមរយៈការសម្រួលដល់ការធ្វើសមាហរណកម្មការងារក្នុងទីផ្សារការងារក្នុងស្រុក ដោយតាមរយៈវគ្គបណ្តុះ បណ្តាលវិជ្ជាជីវៈ ការប្រឹក្សាពីអាជីព ឱកាសការងារ និងការគាំទ្រសហគ្រិនភាព។ ស្ថាប័នទាំងពីរបានឯកភាពក្នុងការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ក្នុងគោលបំណង គាំទ្រដល់ជនទេសន្តរប្រវេសន៍ការងារខ្មែរវិលត្រឡប់មកពីបរទេស ដើម្បីរៀនភាសាបរទេស និងបច្ចេកទេសវិជ្ជាជីវៈ ការផ្តល់ព័ត៌មាន និងត្រៀមរកការងារធ្វើនៅកម្ពុជា និងបណ្តាប្រទេសនានា។

▪ **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ ៖

- បានទទួលជួបពិភាក្សាការងារជាមួយអង្គការមូលនិធិអន្តរជាតិហាការ និងម្ចាស់ជំនួយ ដើម្បីស្វែងយល់អំពីការយន្តការ និងកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារពីការរំលោភបំពានផ្លូវភេទ ក្នុងប្រព័ន្ធអនឡាញ និងនៅក្នុងសហគមន៍

- បានទទួលជួបពិភាក្សាការងារជាមួយអង្គការមេត្រីអន្តរជាតិ(AIM) ស្តីពីតម្រូវការរបស់ជនភៀសសឹក និងការរៀបចំផែនការចុះអប់រំផ្សព្វផ្សាយអំពីការទប់ស្កាត់អំពើជួញដូរមនុស្ស កិច្ចការពារកុមារពីការរំលោភបំពានលើកុមារ នៅតាមមណ្ឌលភៀសសឹក ក្នុងមូលដ្ឋានខេត្តសៀមរាប

- ក្រុមការងារកិច្ចសហប្រតិបត្តិការ (មន្ទីរកិច្ចការនារី) បានទទួលជួបពិភាក្សាការងារស្តីពី អំពើហិង្សាទាក់ទងនឹងយេនឌ័រលើស្ត្រី និងក្មេងស្រី ជាពលករទេសន្តរប្រវេសន៍ ជាមួយអង្គការ UN Women នៅមន្ទីរកិច្ចការនារីខេត្ត។

▪ ខេត្តកណ្តាលៈ លេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាជាមួយ អង្គការខេមរអភិវឌ្ឍន៍សហគមន៍ (KCD) ដើម្បីពិគ្រោះយោបល់ក្នុងការកសាងគម្រោង ពង្រឹងសមត្ថភាពដល់ជនបង្គោលតាមភូមិអោយយល់ដឹងអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពនិងល្បិចកលជនឆបោកនិងដើម្បីការពារប្រជាពលរដ្ឋក្នុងភូមិ។

## គ. ការងារសម្របសម្រួល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន និង លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ បានរៀបចំដឹកនាំសម្របសម្រួល ចូលរួមកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបចំនួន ១៤៥លើក។ (ឧបសម្ព័ន្ធ)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់ៈ

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជាៈ

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ...ដែលធ្វើឱ្យការបូកសរុបទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា។

- ត្រូវការរៀបចំកែលម្អ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់គណៈកម្មាធិការជាតិ គ្រប់លំដាប់ថ្នាក់ ដោយយកចិត្តទុកដាក់បន្ថែមលើការជួញដូរ ដែលពាក់ព័ន្ធនឹងអំពើឆបោកតាមអនឡាញ ដែលមានភាព ស្មុគស្មាញ ដើម្បីឱ្យការធ្វើសកម្មភាព និងទិន្នន័យមានសង្គតិភាព និងកាន់តែជាក់លាក់
- ជនល្មើសមានកលល្បិចខ្ពស់ ក្នុងការធ្វើសកម្មភាពខុសច្បាប់ ជាប្រព័ន្ធ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់ ជាពិសេស នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- ខ្វះការផ្សព្វផ្សាយអំពីលទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលឆ្លើយតបទៅនឹងការចោទប្រកាន់ ជាពិសេស ករណីជនបរទេស
- ខ្វះវិធីសាស្ត្រសមស្រប និងសង្គតិភាពនៃសារអប់រំ ផ្សព្វផ្សាយ និងគម្រោងសកម្មភាពនានា ដែលអាចធ្វើឱ្យការបង្ការទប់ស្កាត់ អំពើជួញដូរ គ្រប់ទម្រង់ ទទួលបានប្រសិទ្ធភាព ដែលអាចឱ្យមនុស្សផ្លាស់ប្តូរឥរិយាបទ មិនធ្វើទេសន្តរប្រវេសន៍ ដោយប្រថុយប្រថាន និងគ្រោះថ្នាក់។

## គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសឆបោកតាមអនឡាញ មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ជនល្មើស និងជនរងគ្រោះ អាចជាមនុស្សតែមួយ ដែលធ្វើឱ្យការកំណត់អត្តសញ្ញាណ មានការលំបាក និងប្រើពេលយូរ។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលត្រូវយកចិត្តទុកដាក់ខ្ពស់ និងចាំបាច់ត្រូវមានការចូលរួមពីបណ្តាក្រសួង ស្ថាប័ន អង្គភាព ពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបញ្ចៀសភាពរងគ្រោះ និងកាត់បន្ថយ សក្តានុពលនៃបទល្មើស។ ការបង្កើនការបង្ការទប់ស្កាត់ នឹងអាចការពារ មនុស្សគ្រប់វ័យ តាំងពីដំណាក់កាលដំបូង។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីចាត់តាំងមន្ត្រីឱ្យទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ដើម្បីទទួលបន្ទុកការងារទំនាក់ទំនង សម្របសម្រួល ការងាររបាយការណ៍ ការងារផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងទទួលបានការបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ចដែល ឆ្លើយតបទៅនឹងការងារប្រឆាំងអំពើជួញដូរមនុស្ស
- ពង្រឹងរបបប្រជុំ ឱ្យបានទៀងទាត់ ដើម្បីបូកសរុប និងតាមដានការងារលទ្ធផលការងារ ដែលអនុវត្ត ផ្អែកលើផែនការ និងយុទ្ធសាស្ត្រដែលបានកំណត់ ពង្រឹងប្រសិទ្ធភាពឬកែលម្អចំណុចខ្វះខាត ក្នុងក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/ស.ប.ជ) ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស និងផ្ញើមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឱ្យបានទាន់ពេលវេលា។

## V. ទិសដៅត្រីមាសទី២ ឆ្នាំ ២០២៦

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួមគឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់

២. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី ខេត្ត

៣. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៤. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត

៥. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេស ការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

៦. ធ្វើវិសោធនកម្មច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍ថ្មីៗនៃអំពើជួញដូរមនុស្សគ្រប់ទម្រង់

៧. បន្តដោះស្រាយឱកាសការងារ មុខរបរ និងការបង្កើតកម្មវិធីបង្កើនប្រាក់ចំណូល តាមវិធីសាស្ត្រជំនាញ និងគោលនយោបាយ នៃវិស័យពាក់ព័ន្ធ ដល់ប្រជាពលរដ្ឋ ជាពិសេស ក្នុងចំណោមជនទេសន្តរប្រវេសន៍វិលត្រឡប់ និងគ្រួសារជនភៀសសឹក

៨. រៀបចកិច្ចប្រជុំវាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨

៩. រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលស្តីពី ទេសន្តរប្រវេសន៍ ជាមួយអ្នកសារព័ត៌មាន និងអ្នកផលិតមាតិកាផ្សេងៗ ក៏ដូចជាមន្ត្រីព័ត៌មាន ដើម្បីជំរុញការផ្សព្វផ្សាយបន្តឱ្យមានប្រសិទ្ធភាព៕

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំមមី អដ្ឋស័ក ព.ស ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ៣ ឆ្នាំ២០២៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ
## ការងារសម្របសម្រួល

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមៈ

- កិច្ចប្រជុំ តាមដានវឌ្ឍនភាពការងារបង្ក្រាបបទល្មើសឆបោក តាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams)
- កិច្ចប្រជុំរាយការណ៍ ស្តីពីការរៀបចំខ្លឹមសារ និងឯកសារពាក់ព័ន្ធ នៃការប្រព្រឹត្តទៅសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ
- ជាអធិបតីក្នុងពិធីបិទ សិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់សាកល្បង នូវគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលបានកែសម្រួលរួច រៀបចំដោយក្រសួងសង្គមកិច្ច នៅខេត្តស្វាយរៀង
- ជាអធិបតី ក្នុងពិធីគាំទ្រជំនួយសម្រាប់តម្រូវការ មូលដ្ឋានដល់គ្រួសារពលករងាយរងគ្រោះ បានវិលត្រឡប់មកពីប្រទេសថៃ រៀបចំដោយអង្គការកោរីតាស់ស្វីស សហការដោយមណ្ឌលទទួលពលករកំរៀង ចំនួនសរុប **២០៧គ្រួសារ** ដោយក្នុងមួយគ្រួសារទទួលបាន ប្រាក់២០ម៉ឺនរៀល ក្នុងនោះស្រុកកំរៀងមាន ៦១គ្រួសារមកពី៦ឃុំ ស្រុកភ្នំព្រឹកមាន ៧២គ្រួសារមកពី៥ឃុំ និងស្រុកសំពៅលូនមាន ៧៤គ្រួសារ មកពី៦ឃុំ
- កម្មវិធីសន្និបាតពិនិត្យលទ្ធផលការងារ ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ និងបូកសរុបចលនាប្រឡងប្រណាំង អនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ឆ្នាំ២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ
- កិច្ចប្រជុំប្រចាំសប្តាហ៍ តាមដានវឌ្ឍនភាពការងារបង្ក្រាបបទល្មើសឆបោក តាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams)
- កម្មវិធី យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៦ ក្រោមប្រធានបទ «ការប្រើប្រាស់បញ្ញាសិប្បនិម្មិត(AI)ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ» នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម(ចំការដូង)
- ជាគណៈអធិបតី សន្និបាតបូកសរុបការងារឆ្នាំ២០២៥ និងលើកទិសដៅឆ្នាំ២០២៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ជាអធិបតី ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅបន្តឆ្នាំ២០២៦ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប
- ជាគណៈអធិបតី ក្នុងកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង
- កិច្ចប្រជុំអន្តរក្រសួងចង្អៀតដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពី «ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា» និងសេចក្តីព្រាងច្បាប់ ស្តីពី «ការបង្ក្រាបអំពើរត់ពន្ធមនុស្ស» នៅទីស្តីការក្រសួងយុត្តិធម៌
- ជាអធិបតីភាព ក្នុងកម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ក្រោមប្រធានបទ «ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ» នៅខេត្តកំពង់ចាម ខេត្តក្រចេះ និងតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជនក្នុងរាជធានីភ្នំពេញ ចំនួន **១២លើក**
- ជាអធិបតីភាព ក្នុងពិធីបិទសិក្ខាសាលាស្តីពី ការចែករំលែកបទពិសោធន៍លើការអនុវត្តន៍ តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន គ.ខ.ប.ជ រវាងខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ នៅខេត្តសៀមរាប
- ជាអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ លើការអនុវត្តកតិកាសញ្ញាពិភពលោកស្តីពី ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅរាជធានីភ្នំពេញ
- ចុះពិនិត្យការងារ ត្រៀមសម្រាប់កម្មវិធីយុទ្ធនាការគាំទ្រ ទិវាសុវត្ថិភាពអ៊ីនធឺណេត ឆ្នាំ២០២៦ ក្រោមប្រធានបទ «ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ» នៅសាលប្រជុំ សាកលវិទ្យាល័យភូមិន្ទកសិកម្ម (ចំការដូង)
- ចុះពិនិត្យវឌ្ឍនភាពនៃការផលិតវីដេអូបទយកការណ៍ សម្រាប់ចាក់បញ្ចាំងនៅក្នុងកម្មវិធី ទិវាជាតិប្រឆាំងការជួញដូរមនុស្ស ដែលត្រូវធ្វើការកែសម្រួល
- កិច្ចប្រជុំប្រចាំសប្តាហ៍ តាមដានវឌ្ឍនភាពការងារបង្ក្រាបបទល្មើសឆបោក តាមប្រព័ន្ធបច្ចេកវិទ្យា (Online Scam)

- កិច្ចប្រជុំតាមប្រព័ន្ធអនឡាញ របស់ប្រទេសជ័យលាភី នៅអាស៊ីប៉ាស៊ីភិច ដើម្បីពិភាក្សាក្នុងការរៀបចំរបាយការណ៍ និងការប្តេជ្ញាចិត្តរួម នៃប្រទេសជ័យលាភីទាំង១០ ត្រៀមចូលរួមក្នុង កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់ នៅទីក្រុងញូយ៉ក
- បានចូលរួមជាអធិបតី ក្នុងពិធីអបអរសាទរទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ «រួមគ្នាដើម្បីកម្ពុជា គ្មានអំពើជួញដូរមនុស្ស និងគ្មានអំពើឆបោកតាមអនឡាញ» នៅខេត្តកំពង់ឆ្នាំង
- ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង
- ជាគណៈអធិបតីក្នុងពិធីបើកយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការ និងទប់ស្កាត់ ការប្រើប្រាស់ពលកម្មកុមារ និងលើកកម្ពស់លក្ខខណ្ឌការងារ សម្រាប់កម្មករនិយោជិតវ័យក្មេងនៅតាមសហគ្រាស នៅខេត្តក្រចេះ
- បានចូលរួមជាអធិបតី ក្នុងពិធីអបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ «រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងគ្មានអំពើឆបោកតាមអនឡាញ» នៅខេត្តសៀមរាប
- ជាអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ លើការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅខេត្តសៀមរាប

- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កិច្ចប្រជុំ ស្តីពីកិច្ចសហការរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង UNODC ROSEAP ពិភាក្សាទៅលើកម្មវិធីជាអាទិភាពក្នុងពេលបច្ចុប្បន្ន ការផ្លាស់ប្តូរ និងចែករំលែកព័ត៌មានទាក់ទងទៅនឹងនិន្នាការថ្មី ព្រមទាំងស្វែងយល់ពីឱកាសក្នុងការពង្រឹងកិច្ចសហការបន្ថែមទៀត នៅក្នុងវិស័យដែលមានផលប្រយោជន៍ និងពង្រឹងសមត្ថភាព ក៏ដូចជាការគាំទ្របច្ចេកទេស ក្នុងការដោះស្រាយបញ្ហាជួញដូរមនុស្ស
  - សិក្ខាសាលាពិគ្រោះយោបល់ត្រីភាគី ស្តីពីការរៀបចំ និងផ្តល់សុពលភាពលើផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៦-២០២៧ ក្នុងការអនុវត្តកម្មវិធីការងារសមរម្យប្រចាំកម្ពុជា (DWCP)
  - កម្មវិធីបើក និងបិទសន្និបាតពិនិត្យលទ្ធផលការងារ ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ និងបូកសរុបចលនាប្រឡងប្រណាំង អនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ឆ្នាំ២០២៦ នៅ ទីស្តីការក្រសួងមហាផ្ទៃ
  - កម្មវិធីពិធីបិទ សន្និបាតបូកសរុបការងារឆ្នាំ២០២៥ និងលើកទិសដៅឆ្នាំ២០២៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  - កិច្ចប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងសេចក្តីព្រាងច្បាប់ស្តីពី ការបង្ក្រាបអំពើរត់ពន្ធ នៅទីស្តីការក្រសួងយុត្តិធម៌
  - ជាគណៈអធិបតី និងធ្វើបទង្ហាញ អំពីសមិទ្ធផលសំខាន់ៗក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ ក្នុងសិក្ខាសាលា ពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូ ឆ្នាំ២០២៦ ដែលសហការរៀបចំដោយក្រសួងយុត្តិធម៌ និង ASEAN-ACT
  - ជាគណៈអធិបតីភាព ក្នុងកម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ក្រោមប្រធានបទ «ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ» នៅខេត្តកំពង់ចាម ខេត្តក្រចេះ និងតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជនក្នុងរាជធានីភ្នំពេញ ចំនួន ១២លើក
  - ជាគណៈអធិបតី ក្នុងកម្មវិធីបើកសិក្ខាសាលាស្តីពី ការចែករំលែកបទពិសោធន៍លើការអនុវត្តន៍ តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន គ.ខ.ប.ជ រវាងខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ
  - ជាគណៈអធិបតី ក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ លើការអនុវត្តកតិកាសញ្ញាពិភពលោកស្តីពី ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់
  - កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសំណើរបស់ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លើខ្លឹមសារនៃសេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃ នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ស្តីពី កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
  - ដឹកនាំ ប្រជុំត្រួតពិនិត្យការងារ ដើម្បីរៀបចំកម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណេត ឆ្នាំ២០២៦ ក្រោមប្រធានបទ "ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ" នៅសាលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង
  - ពិធីអបអរសាទរ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស ១២ធ្នូ ២០២៥ លើកទី១៩ ក្រោមប្រធានបទ រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងគ្មានអំពើឆបោកតាមអនឡាញ ខេត្តសៀមរាប

- ជាអធិបតី ក្នុងកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានតាមអនឡាញ នៅសាលារៀនអន្តរទ្វីបអាមេរិកកាំង (AIS) សាខាជ្រោយចង្វារ ១លើក និងនៅខេត្តកំពង់ចាម ១លើក
- សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ លើការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅខេត្តសៀមរាប
- ជាគណៈអធិបតី ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ប្រចាំឆ្នាំ ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង
- ជាគណៈអធិបតី ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលកិច្ចការពារកុមារ ក្នុងបរិបទទេសន្តរប្រវេសន៍និងផ្សព្វផ្សាយ សេចក្តីណែនាំស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ នៅខេត្តស្ទឹងត្រែង

▪ លេខាធិការដ្ឋាន គ.ជ.ប.ជ
- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (៨៣ច្បាប់) លិខិតចូល (៥៩ច្បាប់)
- លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(៦៩ច្បាប់) លិខិតចូល (៧២ច្បាប់)

▪ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់
- បានប្រជុំត្រៀមរៀបចំកម្មវិធីយុទ្ធនាការ គាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ជាមួយក្រសួង ស្ថាប័ន
- បានប្រជុំពិនិត្យ និងកែសម្រួល សេចក្តីព្រាងផែនការសកម្មភាព ឆ្នាំ២០២៦ របស់ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ដឹកនាំដោយលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ
- បានប្រជុំកម្រិតបច្ចេកទេស រៀបចំមេរៀនគោលសម្រាប់វគ្គបណ្តុះបណ្តាល សៀវភៅស្តីពីក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ និងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨
- បានរៀបចំកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ស្តីពី«ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និង ចំណាកស្រុកដោយគ្មានសុវត្ថិភាព និងជម្រើសមុខរបរ និងការងារ» ១៦លើក មានអ្នកចូលរួមចំនួន ២,៥៥០នាក់
- បានចូលរួមជាមួយក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ដល់មន្ត្រី គ.រ.ប.ជ/គ.ខ.ប.ជ នៅខេត្តស្ទឹងត្រែង និងខេត្តកំពង់ចាម ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ សហការគាំទ្រអង្គការUNICEF ក្រោមគម្រោងជំនួយរបស់សហគមន៍អឺរ៉ុប។

▪ ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍
- បានប្រជុំពិនិត្យ និងកែសម្រួល សេចក្តីព្រាងផែនការសកម្មភាព ឆ្នាំ២០២៦ របស់ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ដឹកនាំដោយលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ
- បានចូលរួមកិច្ចប្រជុំពិនិត្យ និងផ្តល់ធាតុចូលលើកម្រងសំណួរ នៃរបាយការណ៍ ស្តីពីការរកឃើញទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ ឆ្នាំ២០២៥ របស់ក្រសួងការងារ សហរដ្ឋអាម៉េរិក ក្រោមអធិបតីភាព លោកជំទាវ **សួស រដ្ឋាវី** រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសាលប្រជុំ ទីស្តីការក្រសួងការងារ
- បានរៀបចំឯកសារសម្រាប់បើកវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសាទេសន្តរប្រវេសន៍ នៅខេត្តស្ទឹងត្រែង និងខេត្តកំពង់ចាម

▪ ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់សាកល្បង នូវគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អតសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប រៀបចំដោយក្រសួងសង្គមកិច្ច ២លើក (ខេត្តស្វាយរៀង ខេត្តសៀមរាប)
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ប្រមូលធាតុចូល ដើម្បីកសាងប្រភេទសេវា និងចំណាត់ថ្នាក់ប្រភេទករណី ក្នុងប្រព័ន្ធគ្រប់គ្រងករណីរួម រៀបចំអគ្គនាយកដ្ឋានគោលបាយសង្គមកិច្ច (ស.អ.យ)
- បានប្រជុំពិនិត្យ និងកែសម្រួល សេចក្តីព្រាងផែនការសកម្មភាព ឆ្នាំ២០២៦ របស់ក្រុមជំនួយកិច្ចការពារជនរងគ្រោះ
- បានចូលរួមកិច្ចប្រជុំឆ្លងសេចក្តីព្រាងច្បាប់ ស្តីពីអន្តោប្រវេសន៍ថ្មី នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ
- បានចូលរួមកិច្ចប្រជុំពីនិត្យនិងបូកសរុបលទ្ធផលការងារ នៃការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយពលកម្មកុមារ និងបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ ២០១៦-២០២៥ ប្រចាំឆ្នាំ២០២៥ ✓✓

- បានចូលរួមកិច្ចប្រជុំ(ZOOM) គណៈកម្មការសទ្ទានុក្រមបច្ចេកសព្ទ ក្នុងវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៅសាលាបណ្ឌិត្យសភា នគរបាលកម្ពុជា និងសាលប្រជុំ គ.ជ.ប.ជ
- បានចូលរួមសិក្ខាសាលាពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំង ជាមួយដៃគូ ឆ្នាំ២០២៦
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ លើការអនុវត្តកតិកាសញ្ញាពិភពលោកស្តីពី ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។

▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**
- បានប្រជុំផ្ទៃក្នុងត្រួតពិនិត្យ និងបូកសរុបរបាយការណ៍ប្រចាំខែមករា របស់ក្រុមការងារអនុវត្តច្បាប់ ដែលទទួលបានអគ្គស្នងការ ជូនទៅលេខាដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- បានអញ្ជើញក្នុងពិធីអបអរសាទរ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០២៥ លើកទី១៩ ក្រោមប្រធានបទ "រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងគ្មានអំពើឆបោកតាមអនឡាញ" នៅខេត្តកំពង់ឆ្នាំង
- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ប្រចាំឆ្នាំ ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង
- ចូលរួមកម្មវិធីបើកយុទ្ធនាការផ្សព្វផ្សាយថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ការយល់ដឹង "អំពើជួញដូរមនុស្សដើម្បីបង្ខំឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងមជ្ឈមណ្ឌលឆបោក" ធ្លាក់ក្នុងអន្ទាក់ឧក្រិដ្ឋកម្មឆបោក នៅសាលប្រជុំសណ្ឋាគារ SUN&MOON។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**
- បានចូលរួម កម្មវិធីបើកយុទ្ធនាការផ្សព្វផ្សាយថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ការយល់ដឹង «អំពើជួញដូរមនុស្ស ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងមជ្ឈមណ្ឌលឆបោក» នៅសាលប្រជុំ សណ្ឋាគារ SUN&MOON
- បានចូលរួម ប្រជុំត្រួតពិនិត្យសៀវភៅបច្ចេកសព្ទក្នុងវិស័យសន្តិសុខ នៃក្រសួងមហាផ្ទៃ តាមប្រព័ន្ធអនឡាញ
- បានចូលរួម ជំនួបជាមួយ តំណាងអង្គការ IJM ប្រចាំតំបន់ ពិភាក្សាការងារដើម្បីបន្តពង្រឹងកិច្ចសហការ ក្នុងភាពជាដៃគូអភិវឌ្ឍ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្របតាមក្របខណ្ឌយុទ្ធសាស្ត្រជាតិ
- បានចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យវឌ្ឍនភាពការងាររៀបចំសៀវភៅសទ្ទានុក្រមក្នុងវិស័យសន្តិសខ នៅបណ្ឌិត្យសភានគរបាលកម្ពុជា។

▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ**
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់សាកល្បង នូវគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប រៀបចំដោយក្រសួងសង្គមកិច្ច នៅខេត្តស្វាយរៀង
- បានប្រជុំពិនិត្យ និងកែសម្រួល សេចក្តីព្រាងផែនការសកម្មភាព ឆ្នាំ២០២៦ របស់ក្រុមជំនួយកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ ដឹកនាំដោយលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ
- បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារ ត្រៀមរៀបចំពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦
- បានអញ្ជើញចូលរួមកម្មវិធី ផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានតាមអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប. នៅសាលារៀនអន្តរទ្វីបអាមេរិកកាំង (AIS) សាខាជ្រោយចង្វារ រាជធានីភ្នំពេញ
- បានអញ្ជើញចូលរួមពិធីអបអរទិវា ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ក្រោមប្រធានបទ"រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" នៅខេត្តសៀមរាប
- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ប្រចាំឆ្នាំ ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង

▪ **ក្រសួងអប់រំ យុវជន និងកីឡា**
- បានចូលរួមកិច្ចប្រជុំ និងផ្តល់ធាតុចូលលើកម្រងសំណួរនៃ របាយការណ៍ស្តីពី ការរកឃើញទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឆ្នាំ ២០២៥ របស់ក្រសួងការងារសហរដ្ឋអាមេរិក
- សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេងនិងការមានផ្ទៃពោះនៅវ័យជំទង់នៅកម្ពុជា ឆ្នាំ២០២៥-២០៣០
- ប្រជុំស្តីពីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៦ នៅខេត្តក្រចេះ
- បានចូលរួមសិក្ខាសាលាថ្នាក់ជាតិ "ស្តីពី ការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ លើការអនុវត្តកតិកាសញ្ញា ពិភពលោកស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់"
- បានចូលរួមអបអរសាទរទិវាជាតិ១២ធ្នូ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥

- ប្រជុំស្តីពីការកាត់បន្ថយពលកម្មកុមារនិងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារប្រចាំឆ្នាំ២០២៥ នៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានចូលរួមប្រជុំផ្សព្វផ្សាយ និងបូកសរុបរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥

- ក្រសួងព័ត៌មាន៖
  - បានចូលរួមកិច្ចប្រជុំពិនិត្យរៀបចំទិវាគាំទ្រសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៦ សហការ និងចូលរួមយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៦ ក្រោមប្រធានបទ «ការប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ"
  - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦
  - បានចូលរួមកិច្ចប្រជុំ និងផ្តល់ធាតុចូលលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលការងារទេសន្តរ ប្រវេសន៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖
  - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ និងពិនិត្យខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារនៃព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
  - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើកទី១ ស្តីពីការអភិវឌ្ឍគោលការណ៍ណែនាំអាស៊ាន ស្តីពីការពង្រឹងអធិការកិច្ចការងារក្នុងវិស័យនេសាទ តាមប្រព័ន្ធវីដេអូ
  - បានចូលរួមកិច្ចប្រជុំលេខាធិការដ្ឋាន នៃក្រុមការងារអន្តរក្រសួង ទទួលបន្ទុកជំរុញការអនុវត្តផែនទីបង្ហាញផ្លូវរបស់កម្ពុជាសម្រាប់កាតាលីករសកល ស្តីពីការងារសមរម្យ និងគាំពារសង្គមសម្រាប់អន្តរកាលយុត្តិធម៌ (ក.ផ.ក.អ)
  - បានចូលរួមប្រជុំពិភាក្សាជាមួយក្រុមការងារជំនាញនៃក្រសួងផែនការ ស្តីពីការកំណត់អត្តសញ្ញាណពលករទេសន្តរប្រវេសន៍ត្រឡប់មកពីប្រទេសថៃ នៅក្រសួងផែនការ
  - បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូនៃកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) នៅសណ្ឋាគារ Sun & Moon Riverside
  - បានចូលរួមកម្មវិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨ នៅទីស្តីការក្រសួងមហាផ្ទៃ
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការពិនិត្យឡើងវិញនូវរបាយការណ៍ជាតិ ស្តីពីការអនុវត្ត GCM នៅសណ្ឋាគារកាំបូឌីយ៉ាណាភ្នំពេញ
  - បានចូលរួមកិច្ចប្រជុំពិនិត្យលើ ការឆ្លើយសំណួររបស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក ដើម្បីធ្វើការវាយតម្លៃប្រចាំឆ្នាំ ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្រសួងមហាផ្ទៃ
  - បានចូលរួមជាអធិបតីភាពសម្ពោធ មជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ ដែលប្រតិបត្តិដោយអង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ នៅខេត្តសៀមរាប

- សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA)៖
  - បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូនៃកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៦ នៅសណ្ឋាគារ Sun & Moon Riverside
  - បានចូលរួមពិធីចុះហត្ថលេខាលើគម្រោង ស្តីពីការលើកកម្ពស់មុខរបរ និងការងារដល់ពលករចំណាកស្រុកត្រឡប់មកវិញ ដែលរងផលប៉ះពាល់ពីជម្លោះព្រំដែនកម្ពុជា-ថៃ រវាងអង្គការ ILO ជាមួយស្ថានទូតជប៉ុននៅកម្ពុជា នៅស្ថានទូតជប៉ុននៅកម្ពុជា
  - បានចូលរួមកិច្ចប្រជុំជាមួយ អគ្គនាយកដ្ឋានការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អំពីការពង្រឹងយន្តការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងជនទេសន្តរប្រវេសន៍ការងារខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី និងសិង្ហបុរី។

- ក្រសួងកិច្ចការនារី៖
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការពិនិត្យឡើងវិញនូវរបាយការណ៍ជាតិ ស្តីពីការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ Global Compact for Migration (GCM) ក្នុងគោលបំណងបង្ហាញពីការប្តេជ្ញាចិត្តក្នុងការអនុវត្តគោលបំណងចម្បងរបស់ GCM តាមរយៈវិធីសាស្ត្ររបស់រាជរដ្ឋាភិបាល និងសង្គម ដោយពិនិត្យមើលលើវឌ្ឍនភាព ភាពខ្វះចន្លោះ បញ្ហាប្រឈម ក្នុងការអនុវត្ត GCM ជាអាទិភាព ដើម្បីពង្រឹងអភិបាលកិច្ចនៃការធ្វើចំណាកស្រុក ការពារសិទ្ធិជនទេសន្តរប្រវេសន៍ និងលើកកម្ពស់ប្រកបដោយចីរភាព

- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើការឆ្លើយសំណួររបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ដើម្បីធ្វើការវាយតម្លៃប្រចាំឆ្នាំ ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅទីស្តីការក្រសួងមហាផ្ទៃ
- បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមប្រធានបទ «រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ»
- បានចូលរួមជាគណៈអធិបតីនៅក្នុងកិច្ចប្រជុំ ផ្សព្វផ្សាយរបាយការណ៍ជាតិ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។

▪ ខេត្តកណ្តាល៖
- បានចូលរួមប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥ និងលើកទិសដៅការងាបន្តឆ្នាំ ២០២៦ នៅក្រសួងមហាផ្ទៃ
- ចូលរួមបើកវគ្គបំប៉ន ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការឆបោកតាមប្រព័ន្ធអនឡាញ និងទប់ស្កាត់ការប្រើអំពើហិង្សាក្នុងគ្រួសារ តាមប៉ុស្តិ៍នគរបាលនៃអធិការដ្ឋាន និងប៉ុស្តិ៍នគរបាលរដ្ឋបាល។

▪ ខេត្តកោះកុង៖
- បានចូលរួមកិច្ចប្រជុំ ពិនិត្យសេចក្តីព្រាងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥ ដែលរៀបចំដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តាមរយៈប្រព័ន្ធ Zoom
- បានចូលរួមកម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការជាតិការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅឆ្នាំ ២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ។

▪ ខេត្តក្រចេះ៖
- បានចូលរួមកិច្ចប្រជុំពិនិត្យ សេចក្តីព្រាងរបាយការណ៍ថ្នាក់ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំ ២០២៥ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២៦ តាមរយៈប្រព័ន្ធ ZOOM
- បានអញ្ជើញចូលរួមក្នុងកម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ក្រោមប្រធានបទ "ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ" នៅសាលមហោស្រព ខេត្តក្រចេះ។
- បានអញ្ជើញចូលរួមទិវាអបអរសាទរប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ លើកទី១១ ក្រោមប្រធានបទ " រួមគ្នាដើម្បីគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" នៅរាជធានីភ្នំពេញ
- បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ របាយការណ៍ជាតិការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ
- បានអញ្ជើញចូលរួមកម្មវិធីផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រមូលទិន្នន័យពលរដ្ឋ ធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ នៅខេត្តស្ទឹងត្រែង។

▪ ខេត្តកំពង់ចាម៖
- បានអញ្ជើញចូលរួមក្នុងទិវាជាតិប្រឆាំងការជួញដូរមនុស្ស នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការផ្សព្វផ្សាយ សេចក្តីណែនាំ និងការប្រមូលទិន្នន័យពលរដ្ឋទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ដល់មន្ត្រី គ.រ.ប.ជ/គ.ខ.ប.ជ ខេត្តទាំង៥ រួមមានខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ធំ ព្រៃវែង និងខេត្តស្វាយរៀង នៅសាលប្រជុំសាលាខេត្តកំពង់ចាម
- បានចូលរួមសិក្ខាសាលាស្តីពីការប៉ាន់ប្រមាណ ស្វែងយល់បន្ថែមពីចំណេះដឹង ជំនាញបទពិសោធន៍ និងតម្រូវការរបស់មន្ត្រីជួមុខ (នគរបាល ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីផ្នែកសង្គមកិច្ច) ក្នុងការអនុវត្តការងារប្រឆាំងការជួញដូរមនុស្ស នៅសាលប្រជុំសាលាខេត្ត
- បានចូលរួមសិក្ខាសាលាដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិ គ.ជ.ប.ជ សហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) ស្តីពីការចែករំលែកបទពិសោធន៍លើការអនុវត្ត តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន នៅខេត្តសៀមរាប

- **ខេត្តតាកែវៈ** បានចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗនៅក្នុងប្រទេស ទាំងដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០៣លើក។
- **ខេត្តត្បូងឃ្មុំៈ**
  - ចូលរួមកម្មវិធីផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពី ការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ នៅសាលប្រជុំរដ្ឋបាលខេត្តកំពង់ចាម
  - បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីទម្រង់របាយការណ៍ផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស
  - បានចូលរួមវគ្គបណ្តុះបណ្តាល លើទម្រង់របាយការណ៍ ស្តីពីការផ្តល់សេវាគាំពារជនរងគ្រោះដោយអំពើជួញដូមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
  - ចូលរួមទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ ក្រោមប្រធានបទ «រួមគ្នាដើម្បី គ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ»
  - ចូលរួមក្នុងពិធីដាក់ឱ្យដំណើរ ការសៀវភៅ ក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ (MEL) ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨
  - ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ របាយការណ៍ជាតិការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦
  - បានចូលរួមយុទ្ធនាការផ្សព្វផ្សាយថ្នាក់ជាតិស្តីពី ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងលើកកម្ពស់លក្ខខណ្ឌការងារ សម្រាប់កម្មករនិយោជិតវ័យក្មេង ឆ្នាំ២០២៦ នៅស្រុកស្នួលខេត្តក្រចេះ។
- **ខេត្តបាត់ដំបងៈ**
  - បានចូលរួមកិច្ចប្រជុំ ស្តីពីការផ្តល់ធាតុចូលរបាយការណ៍ប្រចាំឆ្នាំ២០២៥ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥ តាមប្រព័ន្ធអនឡាញវីដេអូ និងសម្លេង ZOOM
  - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីបញ្ហាពលករបញ្ជូនត្រឡប់ពីប្រទេសថៃតាមបណ្តាច្រកទ្វារព្រំដែន នៅក្នុងខេត្តបាត់ដំបង មកកាន់មណ្ឌលទទួលពលករកំរៀង និងដំណោះស្រាយតាមប្រព័ន្ធអនឡាញវីដេអូ និងសម្លេង ZOOM
  - បានចូលរួមកិច្ចប្រជុំរៀបចំផែនការអនុវត្តប្រចាំឆ្នាំ និងផ្សព្វផ្សាយសៀវភៅក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៤-២០២៨ នៅទីស្តីការក្រសួមហាផ្ទៃ
  - បានចូលរួមកម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ
  - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ
  - បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពសេវាគាំទ្រដែលមានការយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្តដល់មន្ត្រីថ្នាក់ក្រោមជាតិ ក្នុងការជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះ នៅខេត្តសៀមរាប ដែលមានការចូលរួមពី ខេត្តចំនួន ៧ សរុបអ្នកចូលរួម ៥៥នាក់ ស្រី ២៥នាក់ គាំទ្រដោយអង្គការ World Hope International ។
- **ខេត្តព្រៃវែងៈ**
  - បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ និងប្រកាសសមាសភាពគណៈកម្មាការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា(online Scams)
  - បានចូលរួមផ្សព្វផ្សាយសេចក្តីណែនាំស្តីពី ការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ដល់មន្ត្រី គ.រ.ប.ជ/គ.ខ.ប.ជ នៅខេត្តកំពង់ចាម។
- **ខេត្តមណ្ឌលគិរីៈ**
  - បានចូលរួមកិច្ចប្រជុំពិនិត្យសេចក្តីព្រាងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ តាមប្រព័ន្ធអនឡាញ Zoom

- បានចូលរួមកម្មវិធីប្រកាស ដាក់ឱ្យប្រើប្រាស់ ជាផ្លូវការសៀវភៅតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨ នៅទីស្តីការក្រសួងមហាផ្ទៃ
- បានចូលរួមកម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ។
- បានចូលរួមកម្មវិធីផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរ ប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦ នៅសាលប្រជុំរដ្ឋបាលខេត្តស្ទឹងត្រែង។

- **ខេត្តសៀមរាប៖**
  - បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យអនុវត្តន៍សាកល្បង ស្តីពីគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របដែលបានកែសម្រួល នៅក្នុងខេត្តសៀមរាប
  - បានចូលរួមកិច្ចប្រជុំប្រចាំសប្តាហ៍តាមប្រព័ន្ធZoom ជាមួយក្រសួងមហាផ្ទៃ ដើម្បីតាមដានវឌ្ឍនភាពការងារបង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams)
  - បានចូលរួមកិច្ចប្រជុំសម្របសម្រួលពិនិត្យលើសូចនាករទាំង២២ ចំណុចស្តីពី ការអនុវត្តផែនការកិច្ចការពារកុមារខេត្តប្រចាំត្រីមាសទី៤ ឆ្នាំ២០២៥
  - បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលសិក្សាស្តីពី តម្រូវការរបស់ពលករទេសន្តរប្រវេសន៍វិលត្រឡប់ និងពិធីប្រកាសចាប់ផ្តើមគម្រោង Empowered ការលើកកម្ពស់ឱកាសសេដ្ឋកិច្ចសម្រាប់ស្ត្រីវ័យក្មេងជាពលករទេសន្តរប្រវេសន៍វិលត្រឡប់បានចំនួន នៅរាជធានីភ្នំពេញ
  - បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន នៅរាជធានីភ្នំពេញ
  - ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្រុកក្រឡាញ់ សហការជាមួយអង្គការ កម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) ចែកកញ្ចប់ស្បៀងអាហារ និងអនាម័យឆ្លើយតបបន្ទាន់ ដល់ស្ត្រីពលករទេសន្តរប្រវេសន៍ ចំនួន ២៩៩នាក់ មកពីឃុំចំនួន ៤ គឺឃុំបួរ ឃុំក្រឡាញ់ឃុំ តាអាន ឃុំកំពង់ថ្កូវ នៅសាលាស្រុកក្រឡាញ់

- **ខេត្តស្ទឹងត្រែង៖**
  - សម្របសម្រួល និងចូលរួមវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ រៀបចំដោយ គ.ជ.ប.ជ
  - បានចូលរួមក្នុងកិច្ចប្រជុំជំរុញការអនុវត្តប្រមូលទិន្នន័យទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍តាមប្រព័ន្ធ Zoom។

- **ខេត្តឧត្តរមានជ័យ៖**
  - ចូលរួមកម្មវិធីប្រកាស ដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅតាមដាន វាយតម្លៃ សិក្សាដកពិសោធន៍ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨
  - ចូលរួមទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ«រួមគ្នាដើម្បីកម្ពុជា គ្មានអំពើជួញដូរមនុស្ស និងគ្មានអំពើឆបោកតាមអនឡាញ» នៅរាជធានីភ្នំពេញ
  - ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ
  - ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិស្តីពី ការវាយតម្លៃការអនុវត្តកតិកាសញ្ញាពិភពលោកស្តីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM)» នៅខេត្តសៀមរាប។

- **ខេត្តប៉ៃលិន៖**
  - ចូលរួមកិច្ចប្រជុំតាមដានវឌ្ឍនភាពការងារ បង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) តាមរយៈប្រព័ន្ធ Zoom នៅស្នងការនគរបាលខេត្ត
  - ចូលរួមកិច្ចប្រជុំពិនិត្យសេចក្តីព្រាងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ តាមប្រព័ន្ធ Zoom នៅសាលាខេត្ត
  - ចូលជាអធិបតីកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីយុទ្ធនាការបោសសម្អាតការឆបោក តាមបច្ចេកវិទ្យា(Online Scams) នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត

- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា Online Scams (ក្របខ័ណ្ឌខេត្ត) តាមរយៈ Video Conference នៅសាលប្រជុំធំសាលាខេត្ត
- ចូលរួមកិច្ចប្រជុំគណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា(Online Scams) ដើម្បីត្រួតពិនិត្យវឌ្ឍនភាព ការអនុវត្តការងារ និងលើកទិសដៅបន្តក្នុងការបោសសម្អាតការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ទីស្តីការគណៈរដ្ឋមន្ត្រី
- ចូលរួមកម្មវិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៤-២០២៨ នៅទីស្តីការក្រសួងមហាផ្ទៃ
- ចូលរួមកម្មវិធីទិវាជាតិប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ
- ចូលរួមកិច្ចប្រជុំប្រចាំសប្តាហ៍ ដើម្បីតាមដានវឌ្ឍនភាព ការងារបង្ក្រាបបទល្មើសឆបោកប្រព័ន្ធបច្ចេកវិទ្យា (Online Scams) តាមរយៈប្រព័ន្ធZoom រាល់សប្តាហ៍
- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ
- ចូលរួមជាគណៈអធិបតី ពិធីបើកយុទ្ធនាការផ្សព្វផ្សាយស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងលើកកម្ពស់លក្ខខណ្ឌការងារសម្រាប់កម្មករនិយោជិតវ័យក្មេង នៅតាមសហគ្រាសឆ្នាំ២០២៦ នៅខេត្តក្រចេះ។